# ខោនធី Fresno

## គម្រោងរដ្ឋបាលរៀបចំការបោះឆ្នោត

## សេចក្តីព្រាង ខែវិច្ឆិកា ឆ្នាំ2021


## បានប្រគល់ដោយ៖

James A. Kus ស្មៀនប្រចាំខោនធី Fresno/

## មន្ត្រីចុះឈ្មោះអ្នកបោះឆ្នោត


គម្រោងរដ្ឋបាលរៀបចំការបោះឆ្នោត

## តារាងមាតិកា


I. សេចក្តីផ្តើម និងខ្លឹមសារសង្ខេបអំពីគម្រោង

II. ការអប់រំអ្នកបោះឆ្នោត និងគម្រោងផ្សព្វផ្សាយព័ត៌មាន

- A. ការប្រើប្រាស់សារព័ត៌មាន
- B. សិក្ខាសាលាស្តីពីការអប់រំអ្នកបោះឆ្នោត
- C. វត្តមានសហគមន៍ទូទៅ
- D. ការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយអ្នកបោះឆ្នោត
- E. កញ្ចប់ថវិកាសម្រាប់ការអប់រំ និងការផ្សព្វផ្សាយព័ត៌មាន
- F. សហគមន៍ភាសាភាគតិច
- G. សហគមន៍ជនពិការ

III. គំរូមណ្ឌលបោះឆ្នោត

- A. សន្លឹកឆ្នោតបោះតាមសំបុត្រប្រៃសណីយ៍
- B. មណ្ឌលបោះឆ្នោត
- C. ប្រអប់ដាក់សន្លឹកឆ្នោត
- D. អាចប្រើទូរសព្ទដែលឥតគិតថ្លៃ
- E. អាចចេញចូលបានដោយអ្នកបោះឆ្នោតដែលមានពិការភាព
- F. សន្តិសុខ/ផែនការសម្រាប់គ្រាអាសន្ន
- G. ការសន្សំសំចៃលើការចំណាយ

IV. ឯកសារភ្ជាប់

ឯកសារភ្ជាប់ A – ក្រមស្តីពីការបោះឆ្នោត មាត្រា 4005(a) និងមាត្រាបន្ទាប់/សេចក្តីយោងឆ្លងគ្នាដើម្បីធ្វើផែនការ
ឯកសារភ្ជាប់ B – ស្ថានីយទូរទស្សន៍ និងស្ថានីយវិទ្យុ
ឯកសារភ្ជាប់ C – សារព័ត៌មានបោះពុម្ពផ្សាយ និងសារព័ត៌មានអេឡិចត្រូនិក
ឯកសារភ្ជាប់ D – អង្គការសហគមន៍ ទីក្រុង និងមណ្ឌលពិសេស
ឯកសារភ្ជាប់ E – សារព័ត៌មានសង្គម អាសយដ្ឋាន និងព័ត៌មានអំពីបុស្តិ៍ព័ត៌មាន
ឯកសារភ្ជាប់ F – កិច្ចប្រជុំ/ព្រឹត្តិការណ៍សហគមន៍
ឯកសារភ្ជាប់ G – ដ្យាក្រាមទម្រង់មណ្ឌលបោះឆ្នោត
ឯកសារភ្ជាប់ H – ទីតាំងមណ្ឌលបោះឆ្នោត ម៉ោងដំណើរការ និងផែនទី
ឯកសារភ្ជាប់ I – សមាជិកគណៈកម្មការរៀបចំការបោះឆ្នោត ចំនួនសមាជិក/ភាសានិយាយ
ឯកសារភ្ជាប់ J – ទីតាំងប្រអប់ដាក់សន្លឹកឆ្នោត
ឯកសារភ្ជាប់ K – ពាក្យកាត់ប្រើនៅក្នុងគម្រោង

# I. សេចក្តីផ្តើម

ខោនធី Fresno ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ 1856 ហើយកាលពីប៉ុន្មានឆ្នាំដំបូង មានពលរដ្ឋរស់នៅក្នុងខោនធីចំនួន 4,605 នាក់ ហើយការបោះឆ្នោតត្រូវធ្វើឡើងដោយប្រើសន្លឹកឆ្នោតរាប់ដោយដៃ។ ខោនធីនេះ ចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធចោះប័ណ្ណបោះឆ្នោតនៅក្នុងឆ្នាំ1967។ ចំនួនការចុះឈ្មោះបោះឆ្នោត បានកើនឡើងរហូតដល់ 200,000 នាក់ ក្នុងឆ្នាំ1972 និង 300,000 នាក់ ក្នុងឆ្នាំ1992។ ដោយសារចំនួនអ្នកចុះឈ្មោះបោះឆ្នោតមានការកើនឡើង និងដោយមានប្រព័ន្ធបោះឆ្នោតផ្សេងទៀត ខោនធីចាប់ផ្តើមដាក់ឲ្យប្រើប្រាស់ប្រព័ន្ធបោះឆ្នោតស្កេនលើសន្លឹកឆ្នោត ដែលមានម៉ាស៊ីនរាប់សន្លឹកឆ្នោតនៅតាមមណ្ឌលបោះឆ្នោតនៅក្នុងឆ្នាំ1999។ ត្រឹមឆ្នាំ2012 ចំនួនអ្នកចុះឈ្មោះបោះឆ្នោតបានកើនឡើងដល់ 400,000 នាក់។ នារដូវរងា ឆ្នាំ2020-2021 ខោនធី Fresno បានឆ្លងផុតចំណុចគោល នៃអ្នកបោះឆ្នោតដែលបានចុះឈ្មោះចំនួន 500,000 នាក់ជាលើកដំបូង និងមានអ្នកបោះឆ្នោតសកម្មដែលបានចុះឈ្មោះចំនួន 506,684 នាក់ នៅអំឡុងការបោះឆ្នោតដកតំណែងអភិបាលរដ្ឋ California ថ្ងៃទី14 ខែកញ្ញា ឆ្នាំ2021 ។

អ្នកបោះឆ្នោត ត្រូវបានអនុញ្ញាតឲ្យបោះឆ្នោតតាមសំបុត្រប្រៃសណីយ៍ (VBM) ចាប់តាំងពីឆ្នាំ1962 មកម្ល៉េះ ប្រសិនបើពួកគេបានបំពេញតាមលក្ខណៈវិនិច្ឆ័យជាក់លាក់មួយចំនួន ។ ក្នុងឆ្នាំ2002 រដ្ឋបានអនុម័ត "ការបោះឆ្នោតតាមសំបុត្រដោយពុំចាំបាច់មានហេតុផលណាមួយនោះទេ" ដូចនេះ អ្នកបោះឆ្នោតម្នាក់ៗ អាចជ្រើសរើសបោះឆ្នោតតាមសំបុត្របាន និងអាចក្លាយជាអ្នកបោះឆ្នោតតាម VBM ជាអចិន្ត្រៃយ៍។ នៅក្នុងឆ្នាំ 1990 សន្លឹកឆ្នោតដែលបានបោះរួចចំនួន 20% នៅក្នុងខោនធី Fresno ជាប្រភេទ VBM ហើយចំនួននេះ បានកើនឡើងថេររហូតដល់ 65% នៅក្នុងការបោះឆ្នោតនាខែវិច្ឆិកា ឆ្នាំ2018 ។ ការបោះឆ្នោតពិសេសមួយ ត្រូវបានរៀបចំឡើងនៅដើមឆ្នាំ2019 បង្ហាញថា 86% នៃសន្លឹកឆ្នោតដែលបានបោះរួច ជាប្រភេទសន្លឹកឆ្នោត VBM។ សន្លឹកឆ្នោតបោះតាមសំបុត្រ ត្រូវមានវាយត្រានៅក្នុងស្រោមសំបុត្រ VBM និងមានចុះហត្ថលេខាដោយអ្នកបោះឆ្នោត។ ហត្ថលេខានៅលើស្រោមសំបុត្រសន្លឹកឆ្នោត VBM នីមួយៗ ត្រូវបានគេប្រៀបធៀបផ្ទៀងផ្ទាត់ជាមួយនឹងហត្ថលេខាបញ្ជីចុះឈ្មោះបោះឆ្នោត ហើយត្រូវតែស៊ីគ្នានៅមុនពេលរាប់ថាបានការ ។ នៅអំឡុងពេលជំងឺរាតត្បាត COVID-19 ក្នុងឆ្នាំ2020 រដ្ឋសភា California បានតម្រូវឲ្យអ្នកបោះឆ្នោតសកម្មដែលបានចុះឈ្មោះទាំងអស់ ទទួលបានសន្លឹកឆ្នោតផ្លូវការតាមប្រៃសណីយ៍ ។ លក្ខខណ្ឌតម្រូវនេះត្រូវបានអូសបន្លាយពេលពេញទូទាំងឆ្នាំ2021 ហើយនៅទីបំផុតត្រូវបានជំរុញឲ្យមានជាអចិន្ត្រៃយ៍ដោយសេចក្តីព្រាងច្បាប់នៃសភាតំណាងរាស្ត្រថ្នាក់រដ្ឋ លេខ 37 នៅក្នុងឆ្នាំ2021 ដោយកំណត់ថាគ្រប់ខោនធីទាំងអស់ត្រូវផ្តល់សន្លឹកឆ្នោតផ្លូវការតាមសំបុត្រប្រៃសណីយ៍ មិនថាគំរូបោះឆ្នោតដែលខោនធីប្រើប្រាស់ជាអ្វីនោះទេ ។

នៅក្នុងឆ្នាំ2016 ច្បាប់ព្រឹទ្ធសភាលេខ 450 បានបង្កើតច្បាប់ស្តីពីជម្រើសអ្នកបោះឆ្នោត (VCA) ។ នៅក្នុងឆ្នាំ2018 ខោនធីចំនួនប្រាំបានផ្លាស់ប្តូរទៅប្រើប្រាស់គំរូ VCA (Madera, Napa, Nevada, Sacramento, និង San Mateo ។) គំរូ VCA ចែងថាអ្នកបោះឆ្នោតគ្រប់រូបត្រូវទទួលបានសន្លឹកឆ្នោត VBM ហើយមណ្ឌលបោះឆ្នោតត្រូវផ្លាស់ប្តូរទីតាំងបោះឆ្នោតចាស់ ។ ស្ថិតក្រោមគំរូមណ្ឌលបោះឆ្នោតនេះ នៅក្នុងខែវិច្ឆិកា ឆ្នាំ2018 ខោនធី Fresno មានការិយាល័យបោះឆ្នោតចំនួន 268កន្លែង បើកដំណើរការរយៈពេលមួយថ្ងៃ។ ក្រោមច្បាប់ VCA ខោនធី Fresno បច្ចុប្បន្ននេះមានមណ្ឌលបោះឆ្នោតចំនួន 53កន្លែង ដែលមាន 10កន្លែងបើកដំណើរការរយៈពេល 11ថ្ងៃ និង43កន្លែងបើកដំណើរការរយៈពេលបួនថ្ងៃ រួមទាំងថ្ងៃចុងសប្តាហ៍ ថ្ងៃឈប់សម្រាក និងថ្ងៃបោះឆ្នោតផងដែរ (អំឡុងពេលបោះឆ្នោតទូទាំងរដ្ឋដែលបានកំណត់ជាធម្មតា) ។ ប្រអប់ដាក់សន្លឹកឆ្នោតដែលមានសុវត្ថិភាពចំនួន 65ត្រូវបានបង្កើតឡើង ដែលបើកដំណើរការរយៈពេល 29ថ្ងៃ រួមទាំងថ្ងៃបោះឆ្នោតផងដែរ ។ អ្នកបោះឆ្នោតខោនធី Fresno អាចជ្រើសរើសបោះឆ្នោតដោយផ្ទាល់នៅមណ្ឌលបោះឆ្នោតណាមួយក្នុងចំណោមមណ្ឌលបោះឆ្នោតទាំង 53កន្លែង ហើយនឹងមានផ្តល់ជូនសេវាសំខាន់ៗ រួមទាំងសន្លឹកឆ្នោតតាមការចង់បាន និងការចុះឈ្មោះអ្នកបោះឆ្នោត ។ ទីតាំង

យ៉ាងតិច 109កន្លែង (មណ្ឌលបោះឆ្នោត 53 ប្រអប់ដាក់សន្លឹកឆ្នោត 65 និងការិយាល័យកណ្តាលសម្រាប់ការបោះឆ្នោត) នឹងមានផ្តល់ជូនសម្រាប់ដាក់សន្លឹកឆ្នោតតាមសំបុត្រប្រៃសណីយ៍ ។ អ្នកបោះឆ្នោតក៏អាចផ្ញើសន្លឹកឆ្នោត VBM របស់ពួកគេតាមប្រៃសណីយ៍ដែលមានបង់ថ្លៃបញ្ញើប្រៃសណីយ៍រួចបានផងដែរ ។

គំរូ VCA ផ្តល់ជូនដល់អ្នកបោះឆ្នោតទាំងអស់នូវឱកាសបន្ថែមដើម្បីធ្វើការបោះឆ្នោតរបស់ពួកគេ ។ អ្នកបោះឆ្នោត អាចជ្រើសរើសធ្វើការបោះឆ្នោតនៅមណ្ឌលបោះឆ្នោតណាមួយដែលផ្តល់ជូនដល់អ្នកបោះឆ្នោតគ្រប់រូបនូវរយៈពេលយ៉ាងតិច 93 ម៉ោង ក្នុងអំឡុងពេល 11 ថ្ងៃ នៃរយៈពេលបោះឆ្នោតនៅមណ្ឌលបោះឆ្នោត ប្រៀបធៀបនឹងពេលចំនួន 13 ម៉ោង (មួយថ្ងៃ) ស្ថិតក្រោមគំរូម៉ូឌែលការិយាល័យបោះឆ្នោតពីមុន។ ការបន្ថែមម៉ោងនេះ រួមបញ្ចូលនូវពេលចុងសប្តាហ៍ និងថ្ងៃឈប់សម្រាកផងដែរ។ បន្ថែមលើនេះ សេវាចុះឈ្មោះបោះឆ្នោត នឹងត្រូវផ្តល់ជូននៅតាមមណ្ឌលបោះឆ្នោតទាំងអស់ ផ្ទុយពីការផ្តល់ជូននៅទីតាំងតែមួយ (ការិយាល័យបោះឆ្នោត) ស្ថិតក្រោមគំរូការិយាល័យបោះឆ្នោត ។

នៅក្នុងខែសីហា ឆ្នាំ2018 ខោនធី Fresno បានចេញលិខិតស្នើសុំមួយសម្រាប់សំណើសុំប្រព័ន្ធបោះឆ្នោតថ្មី។ ប្រព័ន្ធដែលមានស្រាប់នេះ ចាំបាច់ត្រូវផ្លាស់ចេញ ដោយសារអាយុកាល និងបញ្ហាលំបាកក្នុងការស្វែងរកគ្រឿងបន្លាស់ថ្មី។ សកម្មភាពនេះអាចដឹងជាមុនយ៉ាងច្បាស់ ដោយសាររដ្ឋបានលុបចោលរាល់ប្រព័ន្ធបោះឆ្នោតទាំងអស់ដែលមិនត្រូវបានបញ្ជាក់ក្រោមលក្ខខណ្ឌតម្រូវបច្ចុប្បន្ន ។ ខោនធីបានរៀបចំកិច្ចប្រជុំសហគមន៍ចំនួនប្រាំលើក ដើម្បីស្វែងយល់ថាតើខោនធី Fresno គួរផ្លាស់ប្តូរទៅប្រើប្រាស់គំរូ VCA ដែរឬអត់ដែលការផ្លាស់ប្តូរនេះនឹងប៉ះពាល់ដល់ការទិញសម្ភារៈបរិក្ខារ ។ យោងតាមកិច្ចប្រជុំសហគមន៍ ការប្រាស្រ័យទាក់ទងជាមួយខោនធីទាំងប្រាំដែលបានផ្លាស់ប្តូរទៅប្រើគំរូ VCA ការិយាល័យរដ្ឋលេខាធិការ និងខោនធីផ្សេងទៀតដែលកំពុងពិចារណាលើការផ្លាស់ប្តូរនេះ លោក Brandi Orth ជាស្មៀនប្រចាំខោនធី Fresno/មន្ត្រីចុះឈ្មោះអ្នកបោះឆ្នោត បានណែនាំដល់គណៈកម្មការអធិការកិច្ចថា ខោនធី Fresno គួរតែផ្លាស់ប្តូរទៅប្រើគំរូ VCA ។ គណៈកម្មការអធិការកិច្ច បានបោះឆ្នោតនៅថ្ងៃទី12 ខែមីនា ឆ្នាំ2019 ដើម្បីធ្វើការចាប់ផ្តើមផ្លាស់ប្តូរប្រព័ន្ធថ្មីនេះ នៅក្នុងការបោះឆ្នោតបឋមជ្រើសរើសបេក្ខជនប្រធានាធិបតីនាខែមីនា ឆ្នាំ2020 ។ ខោនធី Fresno គឺជាខោនធីមួយក្នុងចំណោមខោនធីទាំងដប់ដែលបានផ្លាស់ប្តូរទៅប្រើគំរូ VCA ក្នុងឆ្នាំ2020 ដែលមានខោនធីចំនួនដប់មួយកំពុងគ្រោងរៀបចំអនុវត្តគំរូ VCA នៅក្នុងឆ្នាំ2022 ។

នៅខែមីនា ឆ្នាំ2020 ខោនធី Fresno បានអនុវត្តការបោះឆ្នោតជាលើកដំបូងរបស់ខ្លួនក្រោមគំរូ VCA ។ មណ្ឌលបោះឆ្នោតចំនួន 53កន្លែង និងប្រអប់ដាក់សន្លឹកឆ្នោតចំនួន 44 ត្រូវបានបែងចែកនៅទូទាំងខោនធី ផ្អែកតាមលក្ខណៈវិនិច្ឆ័យនៃក្រមស្តីពីការបោះឆ្នោតរដ្ឋ California ផ្នែក 4005 និងមតិចូលរួមរបស់សហគមន៍។ អ្នកបោះឆ្នោតចំនួន 199,118នាក់ បានចូលរួមក្នុងការបោះឆ្នោត ដោយមាន 13.4% ប្រើប្រាស់មណ្ឌលបោះឆ្នោតក្នុងរយៈពេល 11ថ្ងៃដែលមណ្ឌលបោះឆ្នោតមានផ្តល់ជូន ។ ជំងឺរាតត្បាត COVID-19 បានបង្កបញ្ហាប្រឈមជាក់លាក់នានាទៅលើការអនុវត្តការបោះឆ្នោតកាលពីខែវិច្ឆិកា ឆ្នាំ2020 ប៉ុន្តែគំរូ VCA បានសម្រួលឲ្យមានការបោះឆ្នោតប្រកបដោយសន្តិសុខនិងសុវត្ថិភាព ដែលមានអ្នកបោះឆ្នោតចំនួន 370,068នាក់ ជាអត្រាចូលរួមដ៏ខ្ពស់បំផុតមួយក្នុងរយៈពេលជាងម្ភៃឆ្នាំមកនេះ នៅក្នុងខោនធី Fresno ។ គួរបញ្ជាក់ផងដែរថា សន្លឹកឆ្នោតជាង 160,000 បានប្រគល់ត្រឡប់មកវិញ តាមរយៈប្រអប់ដាក់សន្លឹកឆ្នោតតាមសំបុត្រប្រៃសណីយ៍ ដែលបានប្រើប្រាស់នៅអំឡុងពេលបោះឆ្នោតនាខែវិច្ឆិកា ឆ្នាំ2020 ។

ការបោះឆ្នោតនៅខោនធី Fresno បានបង្កើតគណៈកម្មការផ្តល់ឱវាទច្បាប់ស្តីពីជម្រើសអ្នកបោះឆ្នោតនៅខែមីនា ឆ្នាំ2019 ហើយពីមុនមកធ្លាប់បានបង្កើតគណៈកម្មការផ្តល់ឱវាទសម្រាប់ចូលបោះឆ្នោត (Voter Accessibility Advisory Committee, VAAC) និងគណៈកម្មការផ្តល់ឱវាទផ្នែកប្រើប្រាស់ភាសា (Language Accessibility Advisory Committee, LAAC) ។ គណៈកម្មការទាំងនេះ

បានផ្តល់ការគាំទ្រនិងមតិចូលរួមដ៏សំខាន់សម្រាប់គម្រោងរដ្ឋបាលរៀបចំការបោះឆ្នោតឆ្នាំ2019 របស់ខោនធី ។ គណៈកម្មការ VAAC និង LAAC បានបើកដំណើរការជាបន្តបន្ទាប់នៅអំឡុងឆ្នាំ2019, 2020, និង 2021 ហើយគណៈកម្មការ VCAAC ដែលបានធ្វើកំណែទម្រង់ កំពុងតែសម្របសម្រួលដល់ការអភិវឌ្ឍគម្រោង EAP ដែលបានធ្វើបច្ចុប្បន្នភាពនេះផងដែរ ។

មតិចូលរួមពីកិច្ចប្រជុំសហគមន៍ គណៈកម្មការ VAAC គណៈកម្មការ LAAC និងគណៈកម្មការ VCAAC ត្រូវបានយកមកពិចារណា និងប្រើប្រាស់ដើម្បីបង្កើតគម្រោងរដ្ឋបាលរៀបចំការបោះឆ្នោត(EAP) នេះ ដែលនឹងផ្តល់សេចក្តីលម្អិតអំពីរបៀបដែលខោនធី Fresno នឹងបន្តអនុវត្ត VCA រួមទាំងគម្រោងអប់រំនិងផ្សព្វផ្សាយដល់អ្នកបោះឆ្នោត អនុលោមតាមក្រមស្តីពីការបោះឆ្នោតរដ្ឋ California ផ្នែក 4005(a) និងផ្នែកបន្តបន្ទាប់ ។ សូមមើលឯកសារភ្ជាប់ A សម្រាប់ជាឯកសារយោងទៅលើផ្នែកនៃក្រម និងលក្ខខណ្ឌតម្រូវនៃគម្រោងនេះ ។

<u>ខ្លឹមសារសង្ខេបអំពីគម្រោង ៖</u> ខោនធី Fresno នឹងសហការជាមួយគណៈកម្មការទាំងបីដែលមានសមាសភាពសមាជិកសហគមន៍ (គណៈកម្មការផ្តល់ឱវាទច្បាប់ស្តីពីជម្រើសអ្នកបោះឆ្នោត គណៈកម្មការផ្តល់ឱវាទផ្នែកប្រើប្រាស់ភាសា និងគណៈកម្មការផ្តល់ឱវាទសម្រាប់ការចូលបោះឆ្នោត) និងអ្នកតំណាងសហគមន៍ផ្សេងទៀតនៅពេលយើងបន្តអនុវត្តច្បាប់ស្តីពីជម្រើសអ្នកបោះឆ្នោត ។ កិច្ចប្រឹងប្រែងអប់រំនិងផ្សព្វផ្សាយអ្នកបោះឆ្នោត នឹងប្រើប្រាស់បណ្តាញផ្សព្វផ្សាយផ្សេងៗ រួមទាំងឯកសារបោះពុម្ព បណ្តាញសារព័ត៌មានសង្គម វិទ្យុ និងទូរទស្សន៍ ។ ខោនធី នឹងរៀបចំសិក្ខាសាលាស្តីពីការអប់រំអ្នកបោះឆ្នោត ដើម្បីដាក់បញ្ចូលអ្នកបោះឆ្នោតដែលមានពិការភាព និងមិនចេះភាសាអង់គ្លេសទៅក្នុងគម្រោងនេះដែរ ។ ការធ្វើបទបង្ហាញ និងព័ត៌មាន នឹងមានផ្តល់ជូននៅតាមព្រឹត្តិការណ៍សហគមន៍ជាច្រើន ។ អ្នកបោះឆ្នោតនីមួយៗ នឹងទទួលបានសំបុត្រប្រៃសណីយ៍ចំនួនពីរក្នុងការបោះឆ្នោតដែលបានកំណត់ពេលជាប្រចាំមួយលើក ដែលបកស្រាយបំភ្លឺថាអ្នកបោះឆ្នោតទាំងអស់នឹងទទួលបានសន្លឹកឆ្នោតតាមសំបុត្រប្រៃសណីយ៍ និងជម្រើសរបស់ពួកគេសម្រាប់ការបោះឆ្នោត និងសេវាកម្មដែលមានផ្តល់ជូន ។ ការប្រាស្រ័យទាក់ទងគ្នាទាំងអស់ នឹងត្រូវបកប្រែជាភាសាអេស្ប៉ាញ ដូចមានតម្រូវដោយច្បាប់សិទ្ធិបោះឆ្នោតសហព័ន្ធឆ្នាំ1965 ។ ម្យ៉ាងទៀត ការបញ្ជូនសារនិងព័ត៌មានអ្នកបោះឆ្នោត នឹងត្រូវបានបកប្រែជាភាសានានាដែលតម្រូវដោយក្រមស្តីពីការបោះឆ្នោតរដ្ឋ California ដែលបច្ចុប្បន្ននេះរួមមាន ៖ ប៉ុនចាប៊ី ម៉ុង ចិន កូរ៉េ ខ្មែរ ឡាវ វៀតណាម និងតាហ្គាឡុក (បញ្ជីរាយនាមនេះត្រូវមានការផ្លាស់ប្តូរទៅតាមក្រមស្តីពីការបោះឆ្នោតរដ្ឋ California) ។ កញ្ចប់ឯកសារ VCA ដែលបានធ្វើបច្ចុប្បន្នភាព នឹងមានផ្តល់ជូនដល់ស្ថាប័នដែលអាចប្រើប្រាស់ឯកសារនេះ ដើម្បីផ្តល់ដំណឹងទៅដល់សហគមន៍របស់ពួកគេ ។ តាមរយៈមតិចូលរួមពីគណៈកម្មការទាំងបី និងការពិចារណាដែលតម្រូវចាំបាច់នានា ខោនធីនឹងបន្តធ្វើការវាយតម្លៃលើទីតាំងមណ្ឌលបោះឆ្នោត និងទីតាំងប្រអប់ដាក់សន្លឹកឆ្នោតដែលមានស្រាប់ ឬដែលនឹងអាចមាន ។ មណ្ឌលបោះឆ្នោតនីមួយៗ នឹងអាចចេញចូលបាន ហើយនឹងផ្តល់ជូនសេវាសំខាន់ៗ រួមទាំងសន្លឹកឆ្នោតតាមការចង់បានផងដែរ ដើម្បីឲ្យអ្នកបោះឆ្នោតនៅខោនធី Fresno អាចបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោតណាមួយក៏បាន ។ មណ្ឌលបោះឆ្នោតចំនួនដប់ នឹងបើកដំណើរការរយៈពេល 11ថ្ងៃ និងបន្តបើកដំណើរការរយៈពេល 4ថ្ងៃ រួមទាំងថ្ងៃចុងសប្តាហ៍ ថ្ងៃឈប់សម្រាក និងថ្ងៃបោះឆ្នោត ។ ប្រអប់ដាក់សន្លឹកឆ្នោត នឹងបើកដំណើរការរយៈពេល 29ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

## II. ការអប់រំអ្នកបោះឆ្នោត និងគម្រោងផ្សព្វផ្សាយព័ត៌មាន

ខោនធី Fresno គឺជាខោនធីដែលមានចម្រុះភាពដោយមានទីក្រុងចំនួន 15, សហគមន៍មិនមែនអាជីវកម្ម និងតំបន់ជនបទផ្សេងៗ។ ការអប់រំអ្នកបោះឆ្នោត និងការផ្សព្វផ្សាយព័ត៌មាន នឹងត្រូវធ្វើឡើងដោយប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នាដើម្បីបង្កើនការចូលរួមរបស់អ្នកបោះឆ្នោត និងត្រូវប្រាកដថា អ្នកបោះឆ្នោត និងអ្នកបោះឆ្នោតនាពេលអនាគត ទទួលបានការប្រាស្រ័យទាក់ទងតាមទម្រង់ខុសៗគ្នាជាច្រើន ជាភាសាដែលសមស្រប។

ខោនធី Fresno នឹងចុះបញ្ជីជំនួយរបស់អង្គការសហគមន៍ តំណាងសហគមន៍ និងអ្នកជំនាញសហគមន៍ ដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងឲ្យបានច្រើនបំផុតដើម្បីប្រាស្រ័យទាក់ទងជាមួយសហគមន៍។

A. <u>ការប្រើប្រាស់សារព័ត៌មាន រួមមានបណ្ដាញសារព័ត៌មានសង្គម កាសែត វិទ្យុ និងទូរទស្សន៍</u>

1. <u>សេចក្តីប្រកាសអំពីសេវាសាធារណៈ</u> ៖ ខោនធីបានបង្កើតសេចក្តីប្រកាសអំពីសេវាសាធារណៈ (PSAs) សម្រាប់វិទ្យុនិងទូរទស្សន៍ នៅមុនការបោះឆ្នោតខែមីនា ឆ្នាំ2020 និងបានបង្កើតសេចក្តីបញ្ជាក់សាជាថ្មីទៅលើ PSA ទាំងនោះសម្រាប់ការបោះឆ្នោតនៅខែវិច្ឆិកា ឆ្នាំ2020 ដែលបានរងប៉ះពាល់ដោយជំងឺ COVID-19 ។ ខោនធីនឹងបន្តបង្កើតសេចក្តីបញ្ជាក់សាជាថ្មីអំពី PSA ដោយប្រើឯកសារជោគជ័យពីមុនមកធ្វើជាមូលដ្ឋាន នៅអំឡុងវដ្តនៃការបោះឆ្នោតសំខាន់ៗនៅឆ្នាំ2022 និងឆ្នាំ2024 សម្រាប់ចែកចាយទៅដល់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍នៅក្នុងខោនធី ។ PSA នឹងលើកកម្ពស់ខ្សែទូរសព្ទជំនួយសម្រាប់អ្នកបោះឆ្នោតដោយឥតគិតថ្លៃ ដោយផ្តល់ដំណឹងជាទូទៅដល់អ្នកបោះឆ្នោតអំពីការបោះឆ្នោតនៅពេលខាងមុខ និងជម្រើសបោះឆ្នោតផ្សេងៗ ។ PSA នឹងផ្តល់ដំណឹងដល់អ្នកបោះឆ្នោតអំពីលទ្ធភាពអាចទទួលបានសន្លឹកឆ្នោតបោះតាមសំបុត្រប្រៃសណីយ៍ជាទម្រង់ដែលអាចប្រើប្រាស់បាន និងកិច្ចដំណើរការស្នើសុំសន្លឹកឆ្នោតនោះ ។ PSA នឹងត្រូវបានបង្កើតឡើងជាភាសាអង់គ្លេស អេស្ប៉ាញ ប៉ុនចាប៊ី ម៉ុង ចិន កូរ៉េ ខ្មែរ ឡាវ វៀតណាម និងតាហ្គាឡុក ហើយចែកចាយទៅដល់ស្ថានីយក្នុងស្រុកនានា និងបានប្រើប្រាស់តាមបណ្តាញសារព័ត៌មានសង្គម ។ គណៈកម្មការ LAAC, VAAC និង VCAAC នឹងទទួលបានការប្រឹក្សាយោបល់លើខ្លឹមសារ និងការបកប្រែរបស់ PSA ។

មើលឯកសារភ្ជាប់ B សម្រាប់បញ្ជីស្ថានីយទូរទស្សន៍និងវិទ្យុ ។

2. <u>សារបោះពុម្ពផ្សាយ ៖</u> ខោនធីបានបង្កើតសារបោះពុម្ពផ្សាយចម្រុះផ្សេងៗសម្រាប់ប្រើប្រាស់នៅក្នុងកាសែតព្រឹត្តិបត្រព័ត៌មាន ខិត្តប័ណ្ណ និងឯកសារបន្ថែម ។ ភាពជាដៃគូត្រូវបានបង្កើតឡើងជាមួយ Fresno Bee ដែលជាអង្គការសហគមន៍ចម្រុះ និងបណ្តាទីក្រុងនៃខោនធី Fresno ជាច្រើនទៀតសម្រាប់ការចែកចាយឯកសារបោះពុម្ពផ្សាយ ។ ការពង្រីកភាពជាដៃគូជាមួយអង្គការសហគមន៍ គឺជាការផ្តោតមួយសម្រាប់ខោនធីក្នុងការចាប់ផ្តើមខួបបោះឆ្នោតឆ្នាំ2022 ។ ការឆ្លើយតបទូទៅពីសហគមន៍គឺមិនបានគ្រប់ជ្រុងជ្រោយពីក្នុងឯកសារបោះពុម្ពផ្សាយនោះទេ ប៉ុន្តែការទាក់ទងផ្ទាល់បានបង្កើតនូវទំនាក់ទំនងសំខាន់ៗជាមួយសហគមន៍ ។

   សារបោះពុម្ពផ្សាយ នឹងត្រូវបកប្រែជាភាសាទាំងអស់ដែលតម្រូវឲ្យបកប្រែ ។ សារបោះពុម្ពផ្សាយ នឹងរួមបញ្ចូលខ្សែទូរសព្ទជំនួយសម្រាប់អ្នកបោះឆ្នោត 24 ម៉ោងដែលឥតគិតថ្លៃ និងផ្តល់ដំណឹងដល់អ្នកបោះឆ្នោតអំពីលទ្ធភាពអាចទទួលបានសន្លឹកឆ្នោតបោះតាមសំបុត្រប្រៃសណីយ៍ជាទម្រង់ដែលអាចប្រើប្រាស់បាន និងកិច្ចដំណើរការនៃការស្នើសុំសន្លឹកឆ្នោតនោះ ។ សារបោះពុម្ពផ្សាយ នឹងផ្តល់ដំណឹងដល់អ្នកបោះឆ្នោតអំពីការបោះឆ្នោតនាពេលខាងមុខ និងជម្រើសនៃការបោះឆ្នោតផ្សេងទៀត ។ សារបោះពុម្ពផ្សាយ នឹងចាប់ផ្តើមក្នុងរយៈពេលប្រមាណប្រាំមួយខែមុនពេលបោះឆ្នោត ហើយនឹងបន្តផ្តល់សារផ្សេងៗទៀត

រហូតដល់ពេលបោះឆ្នោត ។ គណៈកម្មការ VCAAC, LAAC និង VAAC នឹងទទួលបានឱកាសពិនិត្យមើលឡើងវិញលើសារបោះពុម្ពផ្សាយ ប្រសិនបើអាចធ្វើបាន ។

សារបោះពុម្ពផ្សាយ នឹងត្រូវបានរចនាជាទំហំខុសៗគ្នា និងត្រូវចែកចាយ និង/ឬផ្ញើអ៊ីម៉ែលទៅកាន់កាសែត, អង្គការសហគមន៍, មន្ត្រីព័ត៌មានសាធារណៈនៅក្នុងខោនធី, នាយកដ្ឋានរបស់ខោនធី, បណ្តាទីក្រុង, ក្រុមហ៊ុនសេវាសាធារណៈ, មណ្ឌលពិសេស, មណ្ឌលសិក្សាធិការ, មហាវិទ្យាល័យ និងសាកលវិទ្យាល័យ, សមាគមអ្នកចូលនិវត្តន៍, និងអង្គការផ្សេងទៀត ដែលមានមធ្យោបាយប្រាស្រ័យទាក់ទង (តាមក្រដាស ឬអេឡិចត្រូនិក) ដែលតាមរយៈនេះ សារទាំងនេះ អាចបង្កើតជាថ្មីបានក្នុងទម្រង់ដែលមានបង្ហាញជូន ឬត្រូវបានចែកចាយជាខិត្តប័ណ្ណផ្សព្វផ្សាយ ។ ខោនធី នឹងផ្តល់ជូននូវសារបោះពុម្ពផ្សាយជូនដល់អង្គការនានាដែលយល់ព្រមចែកចាយសារទាំងនោះ និងស្វែងរកបង្កើតដៃគូជាមួយអង្គការនានាដែលត្រូវការបង្កើតសារនេះជាថ្មីនៅក្នុងព្រឹត្តិបត្រព័ត៌មានបោះពុម្ពផ្សាយ និងព្រឹត្តិបត្រព័ត៌មានអេឡិចត្រូនិក។

សូមមើលឯកសារភ្ជាប់ C សម្រាប់សារព័ត៌មានបោះពុម្ព និងសារព័ត៌មានអេឡិចត្រូនិក។
សូមមើលឯកសារភ្ជាប់ D សម្រាប់បញ្ជីរាយនាមអង្គការសហគមន៍ ទីក្រុង និងមណ្ឌលពិសេស ។

3. <u>បណ្តាញសារព័ត៌មានសង្គម និងវត្តមានអ៊ីនធឺណិត ៖</u> គម្រោងបណ្តាញសារព័ត៌មានសង្គម ត្រូវបានអនុវត្តសម្រាប់ការបោះឆ្នោតនាខែមីនា ឆ្នាំ2020 ដោយមានគម្រោងបច្ចុប្បន្នភាពថ្មីៗដែលបានបង្កើតឡើង និងអនុវត្តសម្រាប់ការបោះឆ្នោតខែវិច្ឆិកា ឆ្នាំ2020 ។ គម្រោងទាំងពីរតម្រូវឲ្យមានការប្រើប្រាស់សារសំខាន់ៗដែលជំរុញដល់ការផ្សព្វផ្សាយដល់សមាជិកសហគមន៍ ដោយសារតែភាពជាដៃគូខាងក្រៅអង្គការក្នុងខោនធីគឺមានចំនួនកំណត់ ។ ការរួមបញ្ចូលនូវឯកសារទំនាក់ទំនងបែបវិជ្ជាជីវៈដែលការិយាល័យរដ្ឋលេខាធិការនៃរដ្ឋ Californiaបានផ្តល់ជូន គឺជាសេចក្តីបន្ថែមដ៏សំខាន់ពីលើសារដែលបង្កើតឡើងក្នុងស្រុក និងបានបង្កើតកម្រិតទំនាក់ទំនងកាន់តែល្អប្រសើរនៅអំឡុងការបោះឆ្នោតខែវិច្ឆិកា ឆ្នាំ2020 និងការបោះឆ្នោតខែកញ្ញា ឆ្នាំ2021 ។

   គម្រោងបណ្តាញសារព័ត៌មានសង្គម និងប្រតិទិនខ្លឹមសារផ្សព្វផ្សាយ នឹងបន្តយកទៅប្រើប្រាស់សម្រាប់ខួបបោះឆ្នោតនីមួយៗនៅក្នុងឆ្នាំ2022 និងឆ្នាំ2024 ។ ការពង្រីកការរួមបញ្ចូលជាមួយនឹងដៃគូសហគមន៍ និងអ្នកដែលមានឥទ្ធិពលក្នុងស្រុក នឹងក្លាយជាអាទិភាពដើម្បីធ្វើឲ្យមានឥទ្ធិពលកាន់តែល្អប្រសើរឡើងទៅលើការបញ្ជូនសារលើបណ្តាញសារព័ត៌មានសង្គមតាមខោនធី ។

   ខោនធីកំពុងស្វែងរកការអនុវត្តឆាណែលបណ្តាញសង្គម YouTube យ៉ាងពិសេសសម្រាប់ការចែកចាយសារជាទម្រង់រូបភាពវីដេអូ ។ ឯកសារដែលនឹងអាចមានផ្តល់ជូនដែលត្រូវបានចែកចាយតាមវិធីនេះ អាចនឹងរួមបញ្ចូលនូវការថតខ្សែអាត់សំឡេងសិក្ខាសាលានិងការប្រជុំ ឯកសារបណ្តុះបណ្តាលសម្រាប់បុគ្គលិក និងវីដេអូពន្យល់ខ្លីៗក្រោមប្រធានបទស្តីពី VCA និងការបោះឆ្នោត ។ ឯកសារដែលចែកចាយបែបនេះ អាចនឹងមានផ្តល់ជូនដល់ដៃគូសហគមន៍និងសាធារណជន និងអាចរួមបញ្ចូលទៅក្នុងបណ្តាញសារព័ត៌មានសង្គមផ្សេងទៀតតាមការចាំបាច់ ។

4. <u>គេហទំព័រ ៖</u> គេហទំព័រស្មៀនប្រចាំខោនធី គឺមានជាទម្រង់ដែលអាចចូលប្រើប្រាស់បាន និងមានផ្តល់ជូនជាសាធារណៈ ។ ទំព័រលែនឌីង VCA ជាក់លាក់ គឺមានផ្តល់ជូននៅលើគេហទំព័រ ហើយរួមបញ្ចូលព័ត៌មានទូទៅនិងជាក់លាក់ រួមទាំងគម្រោងរដ្ឋបាលរៀបចំការបោះឆ្នោត បទបង្ហាញ និងបណ្តាញសារព័ត៌មាន

ដែលពាក់ព័ន្ធ ។ ឯកសារ VCA ជាក់លាក់បន្ថែមទៀតស្តីពីការបោះឆ្នោត គឺមានផ្តល់ជូននៅលើទំព័រព័ត៌មានស្តីពីការបោះឆ្នោតនីមួយៗ ។ សារព័ត៌មានបោះពុម្ពផ្សាយ នឹងមាននៅលើគេហទំព័រ ដើម្បីអាចទាញយកនិងចែករំលែកសារព័ត៌មានបោះពុម្ពផ្សាយនោះបាន ។ សេចក្តីប្រកាសអំពីសេវាសាធារណៈទាំងអស់ នឹងមាននៅលើគេហទំព័រស្មៀនប្រចាំខោនធី ។ រាល់ព័ត៌មានជាលាយលក្ខណ៍អក្សរទាំងអស់នៅលើគេហទំព័រ នឹងមានផ្តល់ជូនជាទម្រង់ដែលអាចប្រើប្រាស់បាន ។

5. <u>កញ្ចប់ឯកសារ VCA ៖</u> ខោនធីនឹងផ្តល់កញ្ចប់ឯកសារមួយដែលរួមបញ្ចូលនូវសំណៅចម្លងបណ្តាញសារព័ត៌មានសង្គម ការផ្សព្វផ្សាយឯកសារបោះពុម្ព តំណភ្ជាប់ទៅកាន់បទបង្ហាញ PowerPoint និងឯកសារផ្សេងទៀត ។ ឯកសារ VCA ជាកញ្ចប់ នឹងត្រូវបានបកប្រែជាភាសាដែលបានកំណត់ទាំងអស់ ដែលមានផ្តល់ជូនក្នុងរយៈពេល 90ថ្ងៃជាកំណត់ នៅមុនពេលបោះឆ្នោតធំៗទាំងអស់ អាស្រ័យលើលក្ខខណ្ឌតម្រូវពេលវេលានៃការបកប្រែ ។ កញ្ចប់ឯកសារ VCA នឹងមានផ្តល់ជូននៅលើគេហទំព័រស្មៀនប្រចាំខោនធីនៅក្នុងផ្នែក VCA ។

មើលឯកសារភ្ជាប់ E សម្រាប់ខិត្តប័ណ្ណផ្សព្វផ្សាយ និងអាសយដ្ឋានបណ្តាញសារព័ត៌មានសង្គម ។

**B.** <u>សិក្ខាសាលាស្តីពីការអប់រំអ្នកបោះឆ្នោត</u>

1. <u>សិក្ខាសាលាសហគមន៍ជនពិការ ៖</u> ខោនធីបានរៀបចំសិក្ខាសាលាជនពិការពេញមួយថ្ងៃ/កម្មវិធីបើកទស្សនកិច្ចស្វាគមន៍ (Open House) ដែលមានមជ្ឈមណ្ឌលបោះឆ្នោតគំរូ និងការធ្វើបទបង្ហាញដែលផ្តោតលើការបង្កើនលទ្ធភាពចូលបោះឆ្នោត និងការចូលរួមរបស់អ្នកបោះឆ្នោតដែលមានពិការភាព សម្រាប់ការបោះឆ្នោតនៅខែមីនា ឆ្នាំ2020 ។ កម្មវិធីបើកទស្សកិច្ចស្វាគមន៍នេះ ត្រូវបានចូលរួម និងទទួលស្វាគមន៍ដោយសហគមន៍ ។ ដោយសារតែជំងឺរាតត្បាត COVID-19 សិក្ខាសាលាសម្រាប់ការបោះឆ្នោតខែវិច្ឆិកា ឆ្នាំ2020 និងខែកញ្ញា ឆ្នាំ2021 ត្រូវបានធ្វើឡើងតាមអនឡាញ ដោយរួមសហការជាមួយដៃគូសហគមន៍ ។

   ដោយសារតែភាពជោគជ័យនៃកម្មវិធីបើកទស្សនកិច្ចស្វាគមន៍នៅខែមីនា ឆ្នាំ2020 ខោនធីមានបំណងវិលត្រឡប់ទៅកាន់ទម្រង់ជួបជុំដោយផ្ទាល់វិញ ប្រសិនបើអាចធ្វើបាន ។ មិនថាសិក្ខាសាលានាពេលអនាគតត្រូវបានរៀបចំឡើងដូចម្តេចនោះទេ រាល់សិក្ខាសាលាទាំងអស់នឹងត្រូវបានផ្សព្វផ្សាយជាមុនទៅដល់សហគមន៍ជនពិការ តាមរយៈគណៈកម្មការ VAAC និងការអញ្ជើញដោយផ្ទាល់ទៅដល់ក្រុមអ្នកតស៊ូមតិ និងកម្មវិធីនានាដែលនឹងលើកទឹកចិត្តឲ្យមានការកំណត់ពេល "ធ្វើទស្សនកិច្ចសិក្សា" ឬសកម្មភាពចូលរួមតាមអនឡាញដែលរៀបចំបានត្រឹមត្រូវ ។ ដោយការប្រើប្រាស់គណៈកម្មការ VAAC ខោនធីនឹងធ្វើការជាមួយនឹងបុគ្គល និងក្រុមដែលតំណាងឲ្យសហគមន៍ទាំងនេះ ដើម្បីប្រាកដថាសិក្ខាសាលាត្រូវបានកំណត់ទីតាំង និងរៀបចំបុគ្គលិកសមស្របតាមយុទ្ធសាស្ត្រ ដើម្បីបង្កើតសិក្ខាសាលាដែលមានភាពរីករាយ និងប្រកបដោយប្រសិទ្ធភាព ។ សិក្ខាសាលានឹងរៀបចំឡើងក្នុងរយៈពេលប្រហែល 90ថ្ងៃ មុនពេលបោះឆ្នោតនីមួយៗនាពេលខាងមុខមកដល់ ។

2. <u>សិក្ខាសាលាពីរភាសា ៖</u> ខោនធីបានរៀបចំសិក្ខាសាលាពីរភាសា នៅមុនការបោះឆ្នោតខែមីនា ឆ្នាំ2020 ការបោះឆ្នោតខែវិច្ឆិកា ឆ្នាំ2020 ការបោះឆ្នោតខែមីនា ឆ្នាំ2021 និងការបោះឆ្នោតខែកញ្ញា ឆ្នាំ2021 ។ សិក្ខាសាលាដោយផ្ទាល់ ត្រូវបានរៀបចំឡើងជាមួយនឹងដៃគូសហគមន៍សម្រាប់ការបោះឆ្នោតខែមីនា ឆ្នាំ2020 ប៉ុន្តែជំងឺរាតត្បាត COVID-19 បានបង្ខំឲ្យសិក្ខាសាលាភាគច្រើនដែលបានរៀបចំសម្រាប់ការបោះឆ្នោតផ្សេងទៀតឲ្យប្រព្រឹត្តទៅជាចម្បងតាមអនឡាញ (សិក្ខាសាលាពីរភាសាតាមអនឡាញមួយចំនួន ត្រូវបានរៀបចំ

នៅតាមទីកន្លែង ឬដោយមានជំនួយពីទីកន្លែងរបស់ដៃគូសហគមន៍) ។ ការចូលរួមទូទៅមានការប្រែប្រួលខុសៗគ្នា ប៉ុន្តែមានពាក់ព័ន្ធយ៉ាងពិតប្រាកដទៅនឹងការគាំទ្រដ៏រឹងមាំពីដៃគូសហគមន៍។

ដោយមានការសហការជាមួយ LAAC និងអង្គការសហគមន៍ ខោនធីនឹងរៀបចំសិក្ខាសាលាអប់រំអ្នកបោះឆ្នោតជាពីរភាសា ដើម្បីអប់រំនិងប្រាស្រ័យទាក់ទងប្រាប់បន្ថែមទៀតអំពីកិច្ចដំណើរការនៃច្បាប់ស្តីពីជម្រើសអ្នកបោះឆ្នោត ដែលយ៉ាងហោចណាស់មានសិក្ខាសាលាមួយប្រព្រឹត្តទៅជាភាសានីមួយៗដូចខាងក្រោម៖ អេស្ប៉ាញ ប៉ុនចាប៊ី ម៉ុង ចិន កូរ៉េ ខ្មែរ ឡាវ វៀតណាម និងតាហ្គាឡុក ។ អ្នកបកប្រែផ្ទាល់មាត់សម្រាប់ភាសាជាក់លាក់ណាមួយ នឹងមានផ្តល់ជូនដើម្បីជួយសម្រួលដល់អ្នកចូលរួម ។ ដោយប្រើប្រាស់ LAAC ខោនធីនឹងសហការជាមួយនឹងបុគ្គល និងក្រុមដែលតំណាងឲ្យសហគមន៍ទាំងនេះ ដើម្បីប្រាកដថាសិក្ខាសាលាត្រូវបានកំណត់ទីតាំង និងរៀបចំបុគ្គលិកសមស្របតាមយុទ្ធសាស្ត្រ ដើម្បីបង្កើតសិក្ខាសាលាដែលមានភាពរីករាយ និងប្រកបដោយប្រសិទ្ធភាព ។ សិក្ខាសាលាទាំងអស់នេះ នឹងត្រូវផ្សព្វផ្សាយទៅក្រុម និងបណ្តាញសារព័ត៌មាននានាដែលធ្វើការដោយផ្ទាល់ជាមួយក្រុមភាសាជាក់លាក់ណាមួយ ។ សិក្ខាសាលាទាំងនេះ នឹងរៀបចំឡើងក្នុងរយៈពេលប្រហែល 90ថ្ងៃ មុនពេលបោះឆ្នោតនីមួយៗនាពេលខាងមុខមកដល់។

**C.** <u>វត្តមានសហគមន៍ទូទៅ</u>

1. <u>គណៈកម្មការផ្តល់ឱវាទ VCA ៖</u> ខោនធីបានបង្កើតគណៈកម្មការផ្តល់ឱវាទច្បាប់ស្តីពីជម្រើសអ្នកបោះឆ្នោត (VCAAC) នៅក្នុងឆ្នាំ2019 ដើម្បីសម្របសម្រួលការបង្កើតគម្រោងរដ្ឋបាលរៀបចំការបោះឆ្នោតច្បាប់ដើមរបស់ខោនធី និងជួយដល់ការអនុវត្តច្បាប់ស្តីពីជម្រើសអ្នកបោះឆ្នោតសម្រាប់ការបោះឆ្នោតខែមីនា ឆ្នាំ2020 ។ VCAAC ត្រូវបានកែទម្រង់ក្នុងឆ្នាំ2021 ដើម្បីជួយដល់ការអភិវឌ្ឍគម្រោង EAP និងធ្លាប់បានជួបប្រជុំ ហើយនឹងជួបប្រជុំជាទៀងទាត់ រហូតដល់ដំណាច់ឆ្នាំ2021 ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដើម្បីបញ្ចប់គម្រោង EAP និងអប់រំដល់សហគមន៍ ។ តាមរយៈកិច្ចខិតខំប្រឹងប្រែងនេះ យើងកំពុងប្រមូលព័ត៌មានអំពីឱកាសជាក់លាក់មួយចំនួនដើម្បីធ្វើទំនាក់ទំនងជាមួយសហគមន៍ទូទៅ ក៏ដូចជាក្រុមភាសាជាក់លាក់ណាមួយ និងសមាជិកសហគមន៍ដែលមានពិការភាព ។

(គេហទំព័ររបស់ខោនធី គឺពិភាក្សានៅផ្នែកខាងលើ និងអាចប្រើប្រាស់បានជាសាធារណៈ ក្នុងនាមជាផ្នែកមួយនៃវត្តមានសហគមន៍ទូទៅ ។)

2. <u>កិច្ចប្រជុំសហគមន៍៖</u> ខោនធី នឹងចូលរួមក្នុងកិច្ចប្រជុំសហគមន៍ និងព្រឹត្តិការណ៍នានាដើម្បីផ្តល់នូវការអប់រំទូទៅ និងព័ត៌មានអំពី VCA ជូនដល់សមាជិកសហគមន៍គ្រប់រូប។ កញ្ចប់ឯកសារ VCA នឹងរួមបញ្ចូលនូវឯកសារធ្វើបទបង្ហាញជាប្រភេទ PowerPoint ដើម្បីប្រើប្រាស់នៅក្នុងកិច្ចប្រជុំជាក្រុម និងការធ្វើបទបង្ហាញជា "តារាង" ដែលត្រូវប្រើប្រាស់នៅក្នុងព្រឹត្តិការណ៍នានា ។ កញ្ចប់ឯកសារនេះនឹងត្រូវបានធ្វើបច្ចុប្បន្នភាពនៅអំឡុងឆ្នាំ2022 និងឆ្នាំ2024 សម្រាប់ប្រើប្រាស់នៅអំឡុងខួបបោះឆ្នោតទាំងនោះ ។ ការធ្វើបទបង្ហាញរបស់យើង និងព័ត៌មានបោះពុម្ពផ្សាយ នឹងត្រូវបានបកប្រែជាភាសាដែលតម្រូវជាចាំបាច់ ។ ខោនធីនឹងខិតខំដាក់ចូលទៅក្នុងរបៀបវារៈកិច្ចប្រជុំដែលបានកំណត់ពេលជាប្រចាំនៅទូទាំងសហគមន៍នេះ។ ខោនធី នឹងស្វែងរកការចូលរួមនៅក្នុងកិច្ចប្រជុំសហគមន៍ដែលបម្រើសេវាជូនដល់សហគមន៍នានា ដែលជាអ្នកនិយាយពីរភាសា និងអ្នកដែលមានពិការភាព។

សូមមើលឯកសារភ្ជាប់ F សម្រាប់បញ្ជីសំខាន់ៗនៃកិច្ចប្រជុំនិងព្រឹត្តិការណ៍សហគមន៍នៅពេលខាងមុខ ។

**D.** ការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយអ្នកបោះឆ្នោត

1. សំបុត្រប្រៃសណីយ៍អ្នកបោះឆ្នោត ៖ បន្ថែមពីលើសៀវភៅណែនាំរបស់ខោនធីអំពីព័ត៌មានអ្នកបោះឆ្នោត (CVIG) និងការប្រគល់សន្លឹកឆ្នោតតាមសំបុត្រប្រៃសណីយ៍ ខោនធីនឹងផ្ញើសំបុត្រយ៉ាងតិចចំនួនពីរតាមប្រៃសណីយ៍ទៅដល់អ្នកបោះឆ្នោតនីមួយៗ សម្រាប់គោលបំណងផ្តល់ព័ត៌មានអំពីការបោះឆ្នោតនាពេលខាងមុខ និងផ្សព្វផ្សាយអំពីខ្សែទូរសព្ទជំនួយអ្នកបោះឆ្នោត 24 ម៉ោងដោយឥតគិតថ្លៃ ។ សំបុត្រប្រៃសណីយ៍ត្រូវបានកំណត់ពេលចន្លោះពី 120 ទៅ 80ថ្ងៃមុនពេលបោះឆ្នោត ប៉ុន្តែនឹងត្រូវបានកែសម្រួលអាស្រ័យលើប្រតិទិនបោះឆ្នោត ។

2. ប័ណ្ណប្រៃសណីយ៍សម្រាប់សន្លឹកឆ្នោតដែលអាចស្វែងរកបាន ៖ គ្រប់អ្នកបោះឆ្នោតដែលបានចុះឈ្មោះទាំងអស់ នឹងទទួលបានប័ណ្ណប្រៃសណីយ៍បង់ប្រាក់តាមប្រៃសណីយ៍ជាមួយនឹងសៀវភៅណែនាំរបស់ខោនធីអំពីព័ត៌មានអ្នកបោះឆ្នោត (CVIG) ជាមួយនឹងសេចក្តីណែនាំអំពីការស្នើសុំឯកសារជាភាសាផ្សេងក្រៅពីភាសាអង់គ្លេស និង/ឬស្នើសុំសន្លឹកឆ្នោត VBM នៅក្នុងទម្រង់ដែលអាចប្រើប្រាស់បាន ។ សេចក្តីណែនាំអំពីរបៀបស្នើសុំការបោះឆ្នោតតាមសំបុត្រប្រៃសណីយ៍ដែលអាចទទួលបានពីចម្ងាយ (RAVBM) នឹងត្រូវរួមបញ្ចូលនូវសៀវភៅណែនាំរបស់ខោនធីអំពីព័ត៌មានអ្នកបោះឆ្នោត ។

3. អ្នកបោះឆ្នោតនិយាយភាសាភាគតិច ៖ ខោនធីនឹងកំណត់សម្គាល់អ្នកបោះឆ្នោតនិយាយភាសាភាគតិចតាមរយៈការជ្រើសរើសការនិយមប្រើប្រាស់ភាសានៅលើទម្រង់បែបបទចុះឈ្មោះរបស់អ្នកបោះឆ្នោត ការទាក់ទងដោយផ្ទាល់តាមរយៈអ្នកបោះឆ្នោត បណ្តាលមកពីយុទ្ធនាការបណ្តាញសារព័ត៌មានរបស់អ្នក និងការធ្វើកិច្ចការជាមួយសហគមន៍ និងប័ណ្ណប្រៃសណីយ៍បង់ថ្លៃប្រៃសណីយ៍រួចដែលបានប្រគល់ត្រឡប់មកវិញ ពីសៀវភៅណែនាំរបស់ខោនធីស្តីពីព័ត៌មានអ្នកបោះឆ្នោត ។ សៀវភៅណែនាំអំពីការបកប្រែសន្លឹកឆ្នោត និងព័ត៌មានជាក់លាក់អំពីការបោះឆ្នោតដែលបានបកប្រែ នឹងត្រូវបានផ្ញើជូនតាមប្រៃសណីយ៍ដល់អ្នកបោះឆ្នោតទាំងនោះ ។

4. សេវាភាសាតាមទូរសព្ទឥតគិតថ្លៃ ៖ អាចប្រើប្រាស់ទូរសព្ទឥតគិតថ្លៃបានសម្រាប់ការជំនួយគាំទ្រក្នុងអំឡុងពេលនៃម៉ោងធ្វើការទាំងអស់ ។ បុគ្គលិកមានផ្តល់ជូនដើម្បីជួយអ្នកហៅទូរសព្ទជាភាសាដែលបានកំណត់ដោយសហព័ន្ធ (ភាសាអេស្ប៉ាញ) និងជាភាសាផ្សេងទៀតដែលបានកំណត់ ។ ខោនធីនឹងផ្តល់សេវាភាសានៅអំឡុងខែមុនថ្ងៃបោះឆ្នោត ដើម្បីផ្តល់ជំនួយដល់អ្នកបោះឆ្នោតជាភាសាផ្សេងៗដែលក្រមស្តីពីការបោះឆ្នោតរដ្ឋ California ផ្នែក 14201 បានកំណត់ ។

ខ្សែទូរសព្ទឥតគិតថ្លៃ 24 ម៉ោង (844) 977-8683
សេវាបញ្ជូនបន្តរដ្ឋ California (វិការៈផ្នែកសម្តីនិងស្តាប់) លេខ 711

**E.** កញ្ចប់ថវិកាសម្រាប់ការអប់រំ និងការផ្សព្វផ្សាយព័ត៌មាន

1. កញ្ចប់ថវិកា ៖ ខោនធីបច្ចុប្បន្នផ្តល់កញ្ចប់ថវិកាត្រឹមតែជាង $3,000,000 ប៉ុណ្ណោះក្នុងការបោះឆ្នោតធំមួយដែលបានកំណត់ពេលធ្វើឡើងក្នុងមួយឆ្នាំសារពើពន្ធ (មិនរាប់ថាជាការបោះឆ្នោតពិសេសដែល

បានប្រកាសឲ្យប្រើប្រាស់ពេញលេញដល់ដែនសមត្ថកិច្ចដែលទទួលខុសត្រូវនោះទេ) ក្នុងចំណោម ទឹកប្រាក់នោះ ទឹកប្រាក់ប្រមាណ $500,000 ត្រូវបានគ្រោងរៀបចំសម្រាប់សកម្មភាពអប់រំនិងផ្សព្វផ្សាយ ក្នុងកិច្ចគាំទ្រដល់គំរូ VCA ។ ទឹកប្រាក់ប្រមាណ $160,000 ត្រូវបានគ្រោងរៀបចំសម្រាប់ការបោះពុម្ពសំបុត្រឆ្លងឆ្លើយដោយផ្ទាល់ដែលមានទឹកប្រាក់បន្ថែមចំនួន $90,000 សម្រាប់ថ្លៃប្រៃសណីយ៍លើសំបុត្រឆ្លងឆ្លើយដោយផ្ទាល់ ។ ទឹកប្រាក់ប្រមាណ $50,000 ត្រូវបានគ្រោងរៀបចំសម្រាប់អ្នកពិគ្រោះយោបល់លើបណ្តាញព័ត៌មាន/ការបញ្ជូនសារ និងការផលិតឯកសារលើបណ្តាញព័ត៌មានថ្មីៗ ។ ទឹកប្រាក់ប្រមាណ $50,000 ត្រូវបានគ្រោងរៀបចំសម្រាប់ការបញ្ជូនសារលើបណ្តាញសារព័ត៌មាន (ទូរទស្សន៍/វិទ្យុ/បណ្តាញសង្គម) ជាឯកសារបោះពុម្ពផ្សាយ ឬទម្រង់អេឡិចត្រូនិកដែលមានបង់ប្រាក់ ។ ទឹកប្រាក់ប្រមាណ $100,000 ត្រូវបានគ្រោងសម្រាប់ការគាំទ្រផ្នែករដ្ឋបាល ឬផ្នែករូបវន្តទៅលើឯកសារបញ្ជូនសារ រួមទាំងការអភិវឌ្ឍការបកប្រែឯកសារ ការបកប្រែផ្ទាល់មាត់ ការបោះពុម្ព និងការផ្ញើសំបុត្រ និងការចែកចាយឯកសារ និងសារអប់រំនិងផ្សព្វផ្សាយ ។ ទឹកប្រាក់ប្រមាណ $50,000 ត្រូវបានគ្រោងរៀបចំសម្រាប់ការគាំទ្រដោយផ្ទាល់ទៅលើសកម្មភាពរបស់ដៃគូសហគមន៍ ក្នុងកិច្ចគាំទ្រដល់ការអនុវត្ត VCA នៅក្នុងខោនធី ។

**F.** <u>សហគមន៍ភាសាភាគតិច</u>

1. <u>លក្ខខណ្ឌតម្រូវភាសា៖</u> អ្នកបោះឆ្នោតរបស់ខោនធី Fresno និយាយភាសាផ្សេងៗខុសៗគ្នា។ ខោនធី Fresno ត្រូវតម្រូវឲ្យផ្តល់ឯកសារបោះឆ្នោត និងជំនួយជាភាសាអេស្ប៉ាញស្ថិតក្រោមច្បាប់សិទ្ធិបោះឆ្នោតសហព័ន្ធ ឆ្នាំ 1965 (52 U.S.C. Sec. 10101 et seq.) ។ ការិយាល័យជំរឿនអាចនឹងផ្លាស់ប្តូរភាសាដែលបានកំណត់ដោយសហព័ន្ធនៅក្នុងរដូវស្លឹកឈើជ្រុះ ឬរដូវរងានៃឆ្នាំ2021 ផ្អែកលើទិន្នន័យជំរឿនឆ្នាំ2020 ហើយខោនធីបានត្រៀមផ្តល់សេវាទៅដល់ផ្នែកភាសាណាមួយដែលតម្រូវឲ្យមាននាពេលថ្មីៗ ។ ម្យ៉ាងទៀត ខោនធី Fresno ត្រូវបានតម្រូវឲ្យផ្តល់ឯកសារនិងជំនួយបោះឆ្នោតជាភាសាផ្សេងទៀតចំនួនប្រាំបីភាសា (ប៉ុនចាប៊ី ម៉ុង ចិន កូរ៉េ ខ្មែរ ឡាវ វៀតណាម និងតាហ្គាឡុក) នៅក្នុងតំបន់ជាក់លាក់នានានៅក្នុងខោនធី ស្របទៅតាមក្រមស្តីពីការបោះឆ្នោតរដ្ឋ California ផ្នែក 14201 ។ ភាសាបន្ថែមទាំងនេះអាចនឹងផ្លាស់ប្តូរនៅក្នុងខែកញ្ញា ឆ្នាំ2021 ហើយខោនធីត្រៀមផ្តល់សេវានានាក្នុងការកំណត់ថ្មីៗទៅលើភាសា ។

2. <u>សេវាពីរភាសា ៖</u> ចំណាត់ការជាក់លាក់របស់យើងពាក់ព័ន្ធនឹងភាសានៃសហគមន៍ដែលមានភាសាភាគតិចត្រូវបានដាក់បញ្ចូលតាមរយៈការអប់រំ និងគម្រោងផ្សព្វផ្សាយនេះ ។ LAAC របស់ខោនធី Fresno មានសមាសភាពជាក្រុមចម្រុះមកពីសមាជិកសហគមន៍ និងដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឲ្យប្រាកដថា យើងកំពុងចាត់វិធានការសមស្របដើម្បីផ្សព្វផ្សាយព័ត៌មានឲ្យបានដល់សហគមន៍ភាសាភាគតិចរបស់យើង ។ បច្ចុប្បន្ននេះ សមាជិកបុគ្គលិកបោះឆ្នោតនិយាយភាសាអេស្ប៉ាញ ប៉ុនចាប៊ី តាហ្គាឡុក និងម៉ុង។ យើងនឹងស្វែងរកបុគ្គលិកផ្តល់ជំនួយបន្ថែម ដែលចេះនិយាយពីរភាសា ហើយនឹងជួលបុគ្គលិកសម្រាប់មណ្ឌលបោះឆ្នោតដែលត្រូវការអ្នកចេះពីរភាសានៅទូទាំងខោនធី ដែលមានការផ្តោតយ៉ាងពិសេសនៅក្នុងតំបន់ ភាសាដែលបានកំណត់ក្នុងខោនធី។ ដូចបានរៀបរាប់ខាងលើ បណ្តាញព័ត៌មានរបស់យើងនឹងត្រូវបានផ្តល់ជូនជាភាសាដែលបានកំណត់ទាំងអស់ និងត្រូវបានផ្តល់ជូនដល់ខ្សែបណ្តាញព័ត៌មានដែលផ្តល់ជូនជាភាសាជាក់លាក់មួយចំនួន ដែលបានរួមបញ្ចូលទៅក្នុងបញ្ជីបណ្តាញព័ត៌មានរបស់យើង (មានភ្ជាប់មកជាមួយ) ។ សិក្ខាសាលាស្តីពីអ្នកបោះឆ្នោតដែលចេះពីរភាសា ត្រូវបានរៀបរាប់នៅផ្នែកខាងលើស្ថិតក្រោមសិក្ខាសាលាស្តីពីការអប់រំអ្នកបោះឆ្នោត ។

G. សហគមន៍ជនពិការ

1. សិក្ខាសាលា/គណៈកម្មការ VAAC ៖ ដូចបានរៀបរាប់ខាងលើនៅក្នុងសិក្ខាសាលាអប់រំអ្នកបោះឆ្នោត យើងនឹងរៀបចំធ្វើសិក្ខាសាលា និង/ឬកម្មវិធីបើកទស្សនកិច្ចស្វាគមន៍សម្រាប់អ្នកបោះឆ្នោតដែលមានពិការភាព និងបុគ្គលនិងអង្គការសហគមន៍ដែលគាំទ្រដល់អ្នកបោះឆ្នោតទាំងនេះ។ គណៈកម្មការ VAAC របស់យើង គឺជាផ្នែកដ៏សំខាន់មួយនៃកិច្ចខិតខំប្រឹងប្រែងរបស់យើង ហើយយើងនឹងបន្តធ្វើការជាមួយគណៈកម្មការ VAAC និងប្រើប្រាស់ជំនាញការរបស់ពួកគេដើម្បីផ្សព្វផ្សាយឲ្យបានដល់សមាជិកនៅក្នុងសហគមន៍របស់យើងដែលមានពិការភាព។ សមាជិករបស់ VAAC ក៏នឹងបម្រើការនៅ VCAAC ផងដែរ។ នៅទូទាំងគម្រោងនេះទាំងមូល យើងមានរួមបញ្ចូលនូវចំណាត់ការរបស់យើងដែលពាក់ព័ន្ធនឹង PSA ដំណើររឿងថ្មីៗ សារព័ត៌មានបោះពុម្ព និងបណ្ដាញសារព័ត៌មានសង្គម ការផ្សព្វផ្សាយព័ត៌មានដល់សហគមន៍ និងគេហទំព័រខោនធី ដែលនឹងផ្តល់ដំណឹងនិងអប់រំដល់អ្នកបោះឆ្នោត ដោយមានការផ្តោតជាសំខាន់លើលទ្ធភាពដែលអាចស្វែងរកបាននូវសន្លឹកឆ្នោតបោះតាមសំបុត្រនៅក្នុងទម្រង់ដែលអាចរកបាន និងដំណើរការស្នើសុំសន្លឹកឆ្នោតនេះ។

# III. គំរូមណ្ឌលបោះឆ្នោត

A. សន្លឹកឆ្នោតបោះតាមសំបុត្រប្រៃសណីយ៍

1. ការបោះឆ្នោតតាមសំបុត្រប្រៃសណីយ៍ (VBM)៖ គ្រប់អ្នកបោះឆ្នោតសកម្មដែលបានចុះឈ្មោះទាំងអស់នៅក្នុងខោនធី Fresno នឹងមានសន្លឹកឆ្នោតបោះតាមសំបុត្រប្រៃសណីយ៍ដែលបានផ្ញើឲ្យពួកគេក្នុងរយៈពេលម្ភៃប្រាំបួនថ្ងៃ មុនពេលបោះឆ្នោត។ សន្លឹកឆ្នោតបោះតាមសំបុត្រប្រៃសណីយ៍ អាចត្រូវបានប្រគល់ត្រឡប់មកវិញតាមសំបុត្រប្រៃសណីយ៍ (បង់ប្រាក់តាមប្រៃសណីយ៍) នៅប្រអប់ដាក់សន្លឹកឆ្នោតណាមួយ ឬនៅតាមមណ្ឌលបោះឆ្នោតណាមួយ។

2. RAVBM (ការបោះឆ្នោតតាមសំបុត្រប្រៃសណីយ៍ដែលចូលបោះឆ្នោតបានពីចម្ងាយ)៖ រាល់អ្នកបោះឆ្នោតសកម្មដែលបានចុះឈ្មោះនៅក្នុងខោនធី Fresno អាចស្នើសុំសន្លឹកឆ្នោតអាចប្រើប្រាស់បាន ពីការិយាល័យបោះឆ្នោត។ សន្លឹកឆ្នោតអាចត្រូវបានចូលទៅប្រើប្រាស់បាននៅលើកុំព្យូទ័ររបស់អ្នកបោះឆ្នោត គូសសញ្ញាដោយប្រើបច្ចេកវិទ្យាជំនួយផ្ទាល់ខ្លួនរបស់អ្នកបោះឆ្នោត ហើយបន្ទាប់មកត្រូវតែបានបោះពុម្ព។ សន្លឹកឆ្នោតនេះ អាចប្រគល់ត្រឡប់មកវិញបាននៅក្នុងលក្ខណៈដូចគ្នានឹងសន្លឹកឆ្នោត VBM ដែរ (តាមសំបុត្រប្រៃសណីយ៍ ប្រអប់ដាក់សន្លឹកឆ្នោត ឬមណ្ឌលបោះឆ្នោត)។ ការបញ្ជូនសារអំពីសេវា RAVBM នឹងត្រូវបានរួមបញ្ចូលទៅលើគេហទំព័រ បណ្ដាញសារព័ត៌មានសង្គម និងសៀវភៅណែនាំព័ត៌មានខោនធី។ ឯកសារនឹងមានផ្តល់ជូនដល់ទីភ្នាក់ងារ និងស្ថាប័នដែលផ្តល់សេវានានាដល់អ្នកដែលមានពិការភាពសម្រាប់ការរួមបញ្ចូលទៅក្នុងការបញ្ជូនសាររបស់ពួកគេទៅដល់អតិថិជននិងសមាជិករបស់ពួកគេ។

3. <u>សំណើសុំផ្លាស់ប្តូរសន្លឹកឆ្នោតជាថ្មី៖</u>គ្រប់អ្នកបោះឆ្នោតទាំងអស់ អាចស្នើសុំជូរសន្លឹកឆ្នោតជាថ្មីបានដោយទូរសព្ទទៅលេខ (559) 600-VOTE (8683), ដោយផ្ញើទូរសារនូវសំណើសុំនោះទៅលេខ (559) 488-3279, ដោយមានវត្តមាននៅមណ្ឌលបោះឆ្នោត ឬនៅការិយាល័យបោះឆ្នោតនោះ។

**B. <u>មណ្ឌលបោះឆ្នោត</u>**

1. <u>ទីតាំងមណ្ឌលបោះឆ្នោត៖</u> នៅក្នុងការបោះឆ្នោតខែមីនា ឆ្នាំ2020 ខោនធីបានប្រើប្រាស់មណ្ឌលបោះឆ្នោតចំនួន 53 នៅក្នុងទីតាំង ដោយបំពេញតាមលក្ខណៈវិនិច្ឆ័យ VCA និងដែលបានណែនាំដោយដៃគូសហគមន៍។ មណ្ឌលបោះឆ្នោតត្រឹមតែក្រោម 40% ប៉ុណ្ណោះដែលតម្រូវឲ្យមានការផ្លាស់ប្តូរថ្មីសម្រាប់ការបោះឆ្នោតនៅខែវិច្ឆិកា ឆ្នាំ2020 ដោយសារតែក្តីបារម្ភដែលបង្កឡើងដោយជំងឺរាតត្បាត COVID-19 ជាចម្បង។ មណ្ឌលបោះឆ្នោតជាង 30កន្លែង ត្រូវបានប្រគល់ត្រឡប់មកសម្រាប់ការបោះឆ្នោតខែកញ្ញា ឆ្នាំ2021 ដែលទីតាំងភាគច្រើនមិនទំនេរ មិនអាចសម្របសម្រួលការជូនដំណឹងខ្លីៗអំពីការបោះឆ្នោតដកតំណែងនោះទេ។ មេរៀនចម្បងដែលបានរៀនសូត្រពីគ្រប់ការបោះឆ្នោតទាំងអស់ដែលបានរៀបចំធ្វើឡើង ចាប់តាំងពីពេលអនុវត្តរបស់ VCA គឺភាពសំខាន់ចាំបាច់នៃការកំណត់ពេលរៀបចំទីតាំងមណ្ឌលបោះឆ្នោតនៅដើមដំបូង ហើយខោនធីគ្រោងរៀបចំបម្រុងទុកទីតាំងក្នុងរយៈពេលប្រាំមួយខែដល់មួយឆ្នាំមុនពេលប្រើប្រាស់ ប្រសិនបើអាចធ្វើបានក្នុងឆ្នាំ2022 និងឆ្នាំ2024។ ពិតមែនតែខោនធីមិនរំពឹងទុកអំពីតម្រូវការសម្រាប់មណ្ឌលបោះឆ្នោតច្រើនជាង 53កន្លែងនៅអំឡុងពេលបោះឆ្នោតណាមួយក្នុងឆ្នាំ2022 ក៏ទីតាំងជំនួសឬបន្ថែមត្រូវបានវាយតម្លៃជាបន្តបន្ទាប់ និងបានបញ្ចូលបន្ថែមទៅក្នុងបញ្ជីរាយនាមទីតាំងមណ្ឌលបោះឆ្នោតដែលអាចមាន។

   ការប្រើប្រាស់លក្ខណៈវិនិច្ឆ័យនិងរូបមន្ត VCA សម្រាប់បង្កើតចំនួនមណ្ឌលបោះឆ្នោត និងការកំណត់ទីតាំងមណ្ឌលបោះឆ្នោត ខោនធីនឹងបន្តធ្វើការដោយផ្ទាល់ជាមួយគណៈកម្មការ VAAC, LAAC និង VCAAC របស់យើង ដើម្បីកំណត់ទីតាំងសម្រាប់មណ្ឌលបោះឆ្នោត។ មណ្ឌលបោះឆ្នោត នឹងត្រូវបែងចែកស្មើគ្នានៅទូទាំងខោនធី ដើម្បីបង្កើតជម្រើសងាយស្រួលបំផុតសម្រាប់អ្នកបោះឆ្នោតនៅតាមទីតាំងដែលអាចចេញចូលបាន នៅជិតបំផុតទៅនឹងផ្លូវសេវាដឹកជញ្ជូនសាធារណៈ។ នេះនឹងក្លាយជាគោលដៅដែលត្រូវមានមណ្ឌលបោះឆ្នោតនៅក្នុងទីតាំងដែលនឹងត្រូវប្រើប្រាស់សម្រាប់ការបោះឆ្នោតនាពេលអនាគត ដើម្បីឲ្យអ្នកបោះឆ្នោតមានភាពស៊ាំទៅនឹងទីតាំងបោះឆ្នោត។ មណ្ឌលបោះឆ្នោត នឹងបើកដំណើរការក្នុងរយៈពេលតិចបំផុត 8ម៉ោង ក្នុងមួយថ្ងៃ និងត្រូវឲ្យបើកដំណើរការចំនួន 13ម៉ោងនៅថ្ងៃបោះឆ្នោត។ មណ្ឌលបោះឆ្នោតទាំងដប់កន្លែង នឹងបើកដំណើរការរយៈពេល 11ថ្ងៃ ហើយមណ្ឌលបោះឆ្នោតបន្ថែមនេះនឹងបើកដំណើរការរយៈពេលបួនថ្ងៃ។

2. <u>សេវាមណ្ឌលបោះឆ្នោត៖</u> មណ្ឌលបោះឆ្នោត នឹងអនុញ្ញាតឲ្យអ្នកបោះឆ្នោតដែលមានសិទ្ធិក្នុងខោនធី Fresno បោះសន្លឹកឆ្នោតដោយផ្ទាល់ ចុះឈ្មោះបោះឆ្នោត ឬធ្វើបច្ចុប្បន្នភាពការចុះឈ្មោះបោះឆ្នោតរបស់ពួកគេ។ ក្នុងអំឡុងពេល 14ថ្ងៃ ភ្លាមៗបន្ទាប់ពីនីតិវិធីបោះឆ្នោត ឬនៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតអាចបំពេញការចុះឈ្មោះបោះឆ្នោតដោយមានលក្ខខណ្ឌ (CVR) និងបោះឆ្នោតលើសន្លឹកឆ្នោតដែលមានលក្ខខណ្ឌ។ អ្នកបោះឆ្នោត នឹងទទួលបានសេវាកម្មកម្រិតខ្ពស់នៅគ្រប់មណ្ឌលបោះឆ្នោតទាំងអស់។ អ្នកបោះឆ្នោត ក៏អាចដាក់សន្លឹកឆ្នោត VBM ដែលបានបោះរួចនៅតាមមណ្ឌលបោះឆ្នោតណាមួយបានផងដែរ។

3. <u>បច្ចេកវិទ្យា៖</u> មណ្ឌលបោះឆ្នោត នឹងត្រូវភ្ជាប់ទៅនឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានបោះឆ្នោត (EIMS) របស់ខោនធី ដើម្បីអនុញ្ញាតឲ្យបុគ្គលិកមណ្ឌលបោះឆ្នោត ធ្វើការផ្ទៀងផ្ទាត់តាមពេលវេលាជាក់ស្តែងអំពីស្ថានភាពនៃការបោះឆ្នោតរបស់អ្នកបោះឆ្នោតម្នាក់ៗ។ សន្លឹកឆ្នោត នឹងត្រូវព្រីនចេញ "តាមតម្រូវការ" ដើម្បីឲ្យអ្នកបោះឆ្នោតម្នាក់ៗទទួលបានសន្លឹកឆ្នោតដែលសមស្រប។

4. <u>អង្គភាពដែលមានផ្លូវចេញចូលសម្រាប់ជនពិការ និងការជ្រើសរើសបុគ្គលិក៖</u> មណ្ឌលបោះឆ្នោត នឹងមានឧបករណ៍សម្រាប់គូសសញ្ញាដែលអាចប្រើប្រាស់បានចំនួនបី (Image Cast X)។ គ្រប់មណ្ឌលបោះឆ្នោតទាំងអស់ នឹងត្រូវអនុលោមតាមច្បាប់ស្តីពីជនជាតិអាមេរិកាំងដែលមានពិការភាព (ADA) ហើយបុគ្គលិកនឹងជួយអ្នកបោះឆ្នោតទៅតាមតម្រូវការជាក់លាក់ណាមួយ។ គ្រប់សេវានៅមណ្ឌលបោះឆ្នោតទាំងអស់ នឹងមានផ្តល់ជូនដល់អ្នកដែលមានពិការភាព។

5. <u>ការរៀបចំបុគ្គលិកមណ្ឌលបោះឆ្នោត៖</u> សមាជិកគណៈកម្មការរៀបចំការបោះឆ្នោតនៅមណ្ឌលបោះឆ្នោត នឹងមានចំនួនចាប់ពីបួននាក់រហូតដល់ 10នាក់ (ស្មើនឹងការងារពេញម៉ោង) អាស្រ័យលើចំនួនអ្នកចូលរួមដែលបានរំពឹងទុក និងទំហំមណ្ឌលបោះឆ្នោត។

6. <u>សេវាភាសា៖</u> សមាជិកក្រុមគណៈកម្មការរៀបចំការបោះឆ្នោតពីរភាសា នឹងត្រូវបានចាត់តាំងទៅតាមមណ្ឌលបោះឆ្នោត ដូចបានតម្រូវដោយច្បាប់សិទ្ធិបោះឆ្នោតសហព័ន្ធ និងដោយរដ្ឋលេខាធិការ។ ម្យ៉ាងទៀត ខោនធីនឹងផ្តល់សេវាបកប្រែតាមទូរសព្ទជាភាសាដែលបានកំណត់ ដើម្បីផ្តល់សេវាបកប្រែនៅតាមមណ្ឌលបោះឆ្នោតទាំងអស់។

   គ្រប់មណ្ឌលបោះឆ្នោតនៅខោនធី Fresno ទាំងអស់ នឹងមានសមាជិកគណៈកម្មការរៀបចំការបោះឆ្នោតដែលចេះនិយាយភាសាអេស្ប៉ាញ។ លើសពីនេះទៀត មណ្ឌលបោះឆ្នោតដែលមានទីតាំងនៅក្នុង ឬនៅជាប់នឹងតំបន់ភាសាដែលក្រមស្តីពីការបោះឆ្នោតរដ្ឋ California ផ្នែក 14201 បានកំណត់ផ្សេងទៀត នឹងមានផ្តល់បុគ្គលិកដែលមានសមាជិកគណៈកម្មការរៀបចំការបោះឆ្នោតដែលចេះនិយាយភាសា(នានា)ដែលបានកំណត់។ រាល់ឯកសារនិងជំនួយបោះឆ្នោតនៅមណ្ឌលបោះឆ្នោតទាំងអស់ នឹងត្រូវបានផ្តល់ជូនជាភាសាអេស្ប៉ាញ។ ឯកសារបកប្រែ និងជំនួយភាសាជាក់លាក់ នឹងត្រូវបានផ្តល់ជូននៅក្នុងមណ្ឌលបោះឆ្នោតដែលស្ថិតនៅក្នុង ឬនៅជាប់នឹងតំបន់ភាសាជាក់លាក់ដែលពាក់ព័ន្ធនឹងក្រមស្តីពីការបោះឆ្នោតរដ្ឋ California ផ្នែក 14201។

7. <u>តូបបោះឆ្នោតដែលអាចចេញចូលបាន៖</u> គ្រប់មណ្ឌលបោះឆ្នោតទាំងអស់ នឹងមានតូបបោះឆ្នោតដែលអាចចេញចូលបាន ដើម្បីឲ្យអ្នកបោះឆ្នោតទាំងអស់អាចបោះឆ្នោតដោយសម្ងាត់និងឯករាជ្យ។

8. <u>ការពិចារណាទៅលើសេវាបោះឆ្នោតចល័ត៖</u> ខោនធីមិនបានដំណើរការទីតាំងចល័តនៅក្នុងឆ្នាំ2020 ឬឆ្នាំ2021 ទេ។ ខោនធីកំពុងខ្នះខ្នែងស្វែងរកការអនុវត្តសេវាបោះឆ្នោតចល័តសម្រាប់ឆ្នាំ2022 អាស្រ័យលើលទ្ធភាពអាចផ្តល់ជូនបាននៃអង្គភាពចល័តដែលសមស្រប និងលទ្ធភាពអាចផ្តល់ជូនបាននៃធនធានហិរញ្ញវត្ថុដែលចាំបាច់សម្រាប់ការទិញ និងការរៀបចំបុគ្គលិកអង្គភាពនោះ។ ខោនធីអាចផ្តល់សេវាចល័តនៅក្នុងតំបន់ដែលមិនអាចមានមណ្ឌលបោះឆ្នោត ដោយសារតែការខ្វះខាតទីកន្លែងសមស្រប ឬស្ថិតក្នុងស្ថានភាពអាសន្នដែលរាំងស្ទះដល់ការបំពេញមុខងារនៃទីតាំងមណ្ឌលបោះឆ្នោតដែលបានគ្រោងរៀបចំតាមធម្មតា។

9. <u>មធ្យោបាយធ្វើដំណើរសាធារណៈ៖</u> មធ្យោបាយធ្វើដំណើរសាធារណៈនៅក្នុងខោនធីនេះ ត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃដល់អ្នកដែលចង់ទៅមណ្ឌលបោះឆ្នោត នៅអំឡុងរយៈពេលបោះឆ្នោតបួនថ្ងៃ នៅអំឡុងពេលបោះឆ្នោតទាំងពីរក្នុងឆ្នាំ2020។ ខោនធីនឹងបន្តកម្មវិធីនេះជាមួយនឹងដៃគូដឹកជញ្ជូន។

សូមមើលឯកសារភ្ជាប់ G សម្រាប់ដ្យាក្រាមទម្រង់មណ្ឌលបោះឆ្នោត
សូមមើលឯកសារភ្ជាប់ H សម្រាប់ទីតាំងមណ្ឌលបោះឆ្នោតដែលធ្លាប់ស្គាល់ (អាចមានការប្រែប្រួល)។
សូមមើលឯកសារភ្ជាប់ I សម្រាប់ចំនួនសមាជិកក្រុមប្រឹក្សាបោះឆ្នោត និងភាសានិយាយ។

**C.** **<u>ប្រអប់ដាក់សន្លឹកឆ្នោត</u>**

1. <u>ទីតាំងនិងចំនួនប្រអប់ដាក់សន្លឹកឆ្នោត៖</u> ខោនធីបានសម្រេចអនុវត្តកម្មវិធីប្រអប់ដាក់សន្លឹកឆ្នោតដែលអាចចេញចូលបាននៅខាងក្រៅក្នុងរយៈពេល 24ម៉ោង ដោយចាប់ផ្តើមនៅខែមីនា ឆ្នាំ2020។ ខោនធីបានបង្កើតប្រអប់ដាក់សន្លឹកឆ្នោតចំនួន 44 សម្រាប់ការបោះឆ្នោតខែមីនា ឆ្នាំ2020 ដោយប្រើប្រាស់ការកំណត់គោលដៅទីតាំងដែលបានណែនាំដោយលក្ខណៈវិនិច្ឆ័យរបស់ VCA និងមតិចូលរួមរបស់សហគមន៍។ សហគមន៍ដែលមិនមានមណ្ឌលបោះឆ្នោតទេ ត្រូវបានផ្តល់អាទិភាពសម្រាប់ការដាក់ប្រអប់ដាក់សន្លឹកឆ្នោត។ កម្មវិធីនេះបានពង្រីកសម្រាប់ការបោះឆ្នោតខែវិច្ឆិកា ឆ្នាំ2020 រហូតដល់ប្រអប់ដាក់សន្លឹកឆ្នោតចំនួន 66 ហើយសន្លឹកឆ្នោតដែលបានប្រគល់ត្រឡប់មកវិញជាង 40% ត្រូវបានប្រមូលតាមរយៈប្រអប់ដាក់សន្លឹកឆ្នោតនៃខោនធី Fresno។ ទីតាំងមួយចំនួនតូចប៉ុណ្ណោះបានដកខ្លួនចេញពីកម្មវិធីក្នុងឆ្នាំ2020 និងឆ្នាំ2021 ដែលមានអត្រាចូលរួមប្រគល់ត្រឡប់មកវិញ 95% នៅក្នុងការបោះឆ្នោតខែកញ្ញា ឆ្នាំ2021។

   នៅពេលប្រើប្រាស់លក្ខណៈវិនិច្ឆ័យនិងរូបមន្ត VCA សម្រាប់បង្កើតចំនួនមណ្ឌលបោះឆ្នោត និងការកំណត់ទីតាំងមណ្ឌលបោះឆ្នោត ខោនធីនឹងបន្តធ្វើការដោយផ្ទាល់ជាមួយគណៈកម្មការ VAAC, LAAC និង VCAAC របស់យើងដើម្បីកំណត់ទីតាំងសម្រាប់មណ្ឌលបោះឆ្នោត។ ប្រអប់ដាក់សន្លឹកឆ្នោត នឹងត្រូវដំណើរការរយៈពេលមិនតិចជាង 29 ថ្ងៃនោះទេ រួមទាំងថ្ងៃបោះឆ្នោតផងដែរ។ ប្រអប់ដាក់សន្លឹកឆ្នោត នឹងត្រូវបើកនៅក្នុងម៉ោងធ្វើការធម្មតាក្នុងកម្រិតអប្បបរមា ប្រសិនបើប្រអប់ទាំងនោះត្រូវបានដាក់នៅក្នុងអគារ ហើយប្រអប់ដាក់សន្លឹកឆ្នោតមួយចំនួនទៀត នឹងត្រូវដាក់នៅខាងក្រៅ និងបើកដំណើរការ 24ម៉ោងក្នុងមួយថ្ងៃ។ គ្រប់ប្រអប់ដាក់សន្លឹកឆ្នោតទាំងអស់ នឹងអនុលោមតាម ADA ឬទុកសម្រាប់តែយានយន្តបើកបរឆ្លងកាត់តែប៉ុណ្ណោះ (ផ្លូវបើកបរឆ្លងកាត់)។

មើលឯកសារភ្ជាប់ J សម្រាប់ទីតាំងប្រអប់ដាក់សន្លឹកឆ្នោតដែលធ្លាប់ដឹងពីមុន (អាចមានការផ្លាស់ប្តូរ)។

**D.** **<u>ការប្រើប្រាស់ទូរសព្ទឥតគិតថ្លៃ</u>**

1. <u>អាចប្រើប្រាស់ទូរសព្ទបាន៖</u> អាចប្រើប្រាស់ទូរសព្ទឥតគិតថ្លៃបានសម្រាប់ជំនួយគាំទ្រក្នុងអំឡុងពេលនៃម៉ោងធ្វើការទាំងអស់។ បុគ្គលិកអាចទំនាក់ទំនងបានដើម្បីជួយដល់អ្នកហៅទូរសព្ទជាភាសាដែលបានកំណត់ដោយសហព័ន្ធ ហើយខោនធីនឹងផ្តល់សេវាភាសានៅអំឡុងខែមុនថ្ងៃបោះឆ្នោត ដើម្បីផ្តល់ជំនួយដល់អ្នកបោះឆ្នោតជាភាសាផ្សេងៗ ដែលក្រមស្តីពីការបោះឆ្នោតរដ្ឋ California ផ្នែក 14201 បានកំណត់។

   ខ្សែទូរសព្ទឥតគិតថ្លៃ 24 ម៉ោង (844) 977-8683
   សេវាបញ្ជូនបន្តរដ្ឋ California (វិការៈផ្នែកសម្តីនិងស្តាប់) លេខ 711

**E.** <u>អាចចេញចូលបានដោយអ្នកបោះឆ្នោតដែលមានពិការភាព</u>

1. <u>VAAC៖</u> VAAC របស់ខោនធី Fresno គឺជាគណៈកម្មការសកម្មមួយ ដែលមានសមាសភាពនៃអ្នកបោះឆ្នោតដែលមានពិការភាព និងសមាជិកសហគមន៍ដែលមានចំណាប់អារម្មណ៍ និងចំណេះដឹងអំពីបញ្ហាប្រឈមនានាដែលអ្នកបោះឆ្នោតដែលមានពិការភាពជួបប្រទះ។ VAAC កំពុងផ្តល់យោបល់ ជំនួយ និងអនុសាសន៍នានាដល់ការបោះឆ្នោតរបស់ខោនធី អំពីរបៀបធ្វើយ៉ាងណាឲ្យអ្នកបោះឆ្នោតដែលមានពិការភាព អាចធ្វើការបោះឆ្នោតបានដោយខ្លួនឯង និងដោយការសម្ងាត់។ VAAC បានចូលរួមយ៉ាងសកម្មក្នុងការផ្លាស់ប្តូរទៅប្រើប្រាស់ VCA នៅក្នុងខោនធី Fresno ហើយបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តជាបន្តទៅលើ VCA។

2. <u>ឧបករណ៍សម្រាប់គូសសន្លឹកឆ្នោតដែលអាចប្រើបាន៖</u> ខោនធី មានការប្តេជ្ញាចិត្តដើម្បីលើកកម្ពស់លទ្ធភាពដែលអាចចេញចូលបាននៅក្នុងដំណើរការនៃការបោះឆ្នោត។ មណ្ឌលបោះឆ្នោត នឹងបំពាក់ទៅដោយឧបករណ៍សម្រាប់គូសសញ្ញាលើសន្លឹកឆ្នោតដែលអាចប្រើប្រាស់បាន (Image Cast X) ដើម្បីផ្តល់ឱកាសដូចគ្នាក្នុងការប្រើប្រាស់និងការចូលរួម ដូចដែលមានផ្តល់ជូនដល់អ្នកបោះឆ្នោតដែលពុំមានពិការភាពដែរ រួមទាំងសមត្ថភាពក្នុងការបោះឆ្នោតដោយសម្ងាត់ និងដោយឯករាជ្យផងដែរ។ គម្រោងអប់រំនិងផ្សព្វផ្សាយនៅក្នុងផ្នែកទីមួយនៃឯកសារនេះ មានរៀបរាប់លម្អិតអំពីគម្រោងសម្រាប់សារព័ត៌មាន និងព័ត៌មានជាក់លាក់អំពីការផ្សព្វផ្សាយលេខទូរសព្ទឥតគិតថ្លៃ និងប្រព័ន្ធបោះឆ្នោតតាមសំបុត្រប្រៃសណីយ៍ដែលអាចចូលបោះឆ្នោតបានពីចម្ងាយ (RAVBM)។

3. <u>ការបោះឆ្នោតដែលអាចចូលបោះឆ្នោតបានពីចម្ងាយ៖</u> រាល់អ្នកបោះឆ្នោតសកម្មដែលបានចុះឈ្មោះក្នុងខោនធី Fresno អាចជ្រើសចូលតាមអនឡាញ តាមរយៈប្រព័ន្ធបោះឆ្នោតតាមសំបុត្រប្រៃសណីយ៍ដែលអាចចូលបោះឆ្នោតបានពីចម្ងាយ (RAVBM) ដើម្បីស្នើសុំសន្លឹកឆ្នោតដែលអាចទាញយកបាន។ RAVBM ផ្តល់ឲ្យអ្នកបោះឆ្នោតនូវលទ្ធភាពក្នុងការស្នើសុំឲ្យបញ្ជូនសន្លឹកឆ្នោត VBM តាមប្រព័ន្ធអេឡិចត្រូនិកទៅដល់អ្នកបោះឆ្នោត ពីគេហទំព័រដែលទទួលបានការអនុញ្ញាត។ សន្លឹកឆ្នោតអេឡិចត្រូនិក អាចទាញយកបានទៅក្នុងកុំព្យូទ័ររបស់អ្នកបោះឆ្នោត គូសដោយប្រើបច្ចេកវិទ្យាជំនួយផ្ទាល់ខ្លួនរបស់អ្នកបោះឆ្នោត ហើយបន្ទាប់មកត្រូវតែបានព្រីនចេញមក។ សន្លឹកឆ្នោត អាចប្រគល់ត្រឡប់មកវិញបាននៅក្នុងលក្ខណៈដូចគ្នានឹងសន្លឹកឆ្នោត VBM ដែរ (តាមសំបុត្រប្រៃសណីយ៍ ប្រអប់ដាក់សន្លឹកឆ្នោត ឬមណ្ឌលបោះឆ្នោត)។

**F.** <u>សន្តិសុខ/ផែនការសម្រាប់គ្រាអាសន្ន</u>

1. <u>សន្តិសុខ៖</u> នៅពេលដែលមណ្ឌលបោះឆ្នោតមិនដំណើរការ ទីតាំងនិងគ្រឿងបរិក្ខារនឹងត្រូវការពារសុវត្ថិភាពតាមរយៈពិធីសារសន្តិសុខដែលមានការធ្វើតេស្តសាកល្បងនិងមានស្រាប់ ដូចជាស្លាកបិតភ្ជាប់ការពារមិនឲ្យមានការរុះរើ និងគ្រឿងបរិក្ខាររក្សាទុកដោយសុវត្ថិភាព។

2. <u>ការបង្ការការរំខាន៖</u> សន្តិសុខ និងគម្រោងសម្រាប់គ្រាមានអាសន្ន គឺត្រូវបានដាក់ឲ្យដំណើរការដើម្បីការពារការរំខានដល់ការបោះឆ្នោត និងដើម្បីធានាថាការបោះឆ្នោត ត្រូវបានប្រព្រឹត្តិទៅដោយត្រឹមត្រូវ។ ប្រភពថាមពលដែលមិនរអាក់រអួល (UPS) នឹងត្រូវបានប្រើប្រាស់ទៅលើឧបករណ៍គូសសន្លឹកឆ្នោតដែលអាចចេញចូលបាន (Image Cast X) យ៉ាងតិចចំនួនមួយ សម្រាប់មណ្ឌលបោះឆ្នោតនីមួយៗ និង UPS ដាច់ដោយឡែកមួយសម្រាប់កន្លែងកំព្យូទ័រត្រួតពិនិត្យវត្តមានយ៉ាងតិចចំនួនមួយ។ ឧបករណ៍រក្សាទុកបម្រុង/គ្រឿងបរិក្ខារជំនួសថ្មី នឹងអាចស្វែងរកបានជាមួយនឹងក្រុមបច្ចេកវិទ្យាព័ត៌មាន (IT) ដែលដើរចុះឡើងនៅក្បែរនោះ។ ការបោះឆ្នោត គឺអាចធ្វើទៅបាននៅអគារ

ការិយាល័យបោះឆ្នោតរបស់ខោនធី ដែលមានម៉ាស៊ីនភ្លើងសម្រាប់ប្រើករណីបន្ទាន់។ មណ្ឌលបោះឆ្នោតទាំងអស់នឹងមានបញ្ជីទីតាំងមណ្ឌលបោះឆ្នោតផ្សេងទៀត ដើម្បីឲ្យអ្នកបោះឆ្នោតអាចបញ្ជូនបន្តទៅកាន់មណ្ឌលបោះឆ្នោតដែលនៅជិតនោះបំផុត ប្រសិនបើចាំបាច់។

**G.** <u>ការសន្សំសំចៃលើការចំណាយ</u>

1. <u>ថ្លៃចំណាយ៖</u> ខោនធី Fresno បានទិញប្រព័ន្ធបោះឆ្នោតថ្មីនៅក្នុងឆ្នាំ2019 ដើម្បីជំនួសឲ្យប្រព័ន្ធដែលមានអាយុកាល 20ឆ្នាំដែលប្រើប្រាស់ពីមុនមក។ តម្លៃទិញសរុបគឺ $2,900,000 សម្រាប់សម្ភារៈការិក្ខារ អាជ្ញាប័ណ្ណ និងការគាំទ្ររយៈពេលប្រាំឆ្នាំ។ ថ្លៃចំណាយលើសម្ភារៈសម្រាប់គំរូទីកន្លែងបោះឆ្នោតតាមមណ្ឌលពីមុនមក ត្រូវបានប៉ាន់ប្រមាណថាមានតម្លៃ $1,600,000 ច្រើនជាងសម្ភារៈបរិក្ខារសម្រាប់គំរូ VCA ដោយសារតែខោនធី Fresno ប្រើប្រាស់តារាងបែងចែកសន្លឹកឆ្នោតនៅតាមទីតាំងបោះឆ្នោត។ ការសន្សំសំចៃលើសម្ភារៈបរិក្ខារនេះ គឺជាការសន្សំសំចៃមួយលើក។

ថ្លៃចំណាយលើការបោះឆ្នោត ត្រូវបានលាយបញ្ចូលគ្នានៅក្រោមគំរូ VCA (មើលតារាង 1)។ ថ្លៃចំណាយសុទ្ធតាមខោនធី (NCC) សម្រាប់ការបោះឆ្នោតជ្រើសរើសបេក្ខភាពប្រធានាធិបតី ខែមីនា ឆ្នាំ2020 គឺនៅក្រោមថ្លៃ NCC នៃការបោះឆ្នោតទូទាំងរដ្ឋទាំងពីរលើក ប៉ុន្តែថ្លៃចំណាយទាំងអស់សម្រាប់ការបោះឆ្នោតសកលជ្រើសរើសប្រធានាធិបតីនៅខែកញ្ញា ឆ្នាំ2020 មានថ្លៃចំណាយខ្ពស់ជាងនេះខ្លាំងគួរឲ្យកត់សម្គាល់។ លក្ខណៈពិសេសនៃការបោះឆ្នោតខែវិច្ឆិកា ឆ្នាំ2020 ធ្វើឲ្យមានការចោទជាសំណួរទៅលើការប្រៀបធៀបមួយចំនួន។ ថ្លៃចំណាយសម្រាប់ការបោះឆ្នោតទូទាំងរដ្ឋនាខែកញ្ញា ឆ្នាំ2021 នឹងត្រូវបានបូកបន្ថែម ប្រសិនបើអាចផ្តល់ជូនបាន។

តារាង 1 - ថ្លៃចំណាយឆ្នាំ2018 - 2021

| ការបោះឆ្នោត | ថ្លៃចំណាយសរុប | ថវិកាជំនួយរដ្ឋនិងសហព័ន្ធ | ថ្លៃចំណាយសុទ្ធក្នុងខោនធី (1) |
|---|---|---|---|
| ខែមិថុនា-ឆ្នាំ2018 | $1,820,000 | | $1,760,000 |
| ខែវិច្ឆិកា-ឆ្នាំ2018 | $2,360,000 | | $1,750,000 |
| ខែមីនា-ឆ្នាំ2020 | $3,150,000 | $980,000 | $1,655,000 |
| ខែវិច្ឆិកា-ឆ្នាំ2020 | $5,740,000 | $2,560,000 | $2,333,000 |
| ខែកញ្ញា-ឆ្នាំ2021 | មិនអាចផ្តល់ជូនបាននៅខែតុលា ឆ្នាំ2021 | | |

1 - ថ្លៃចំណាយសុទ្ធក្នុងខោនធី ក្រោយពេលចេញវិក្កយបត្រទូទាត់ទៅដល់អង្គភាពចូលរួម

ការកើនឡើងនៃថ្លៃចំណាយ ត្រូវបានបញ្ជាក់នៅក្នុងថ្លៃប្រៃសណីយ៍ ថ្លៃចំណាយគាំទ្រផ្នែកបច្ចេកទេស និងឯកសារនិងសកម្មភាពផ្សព្វផ្សាយ។ ថ្លៃចំណាយលើបុគ្គលិក ក៏ខ្ពស់ខ្លាំងគួរឲ្យកត់សម្គាល់នៅក្នុងខែវិច្ឆិកា ឆ្នាំ2020 ផងដែរ។ ការថយចុះត្រូវបានសង្កេតទៅលើថ្លៃបោះពុម្ពឯកសារ ថ្លៃដូសជុលសម្ភារៈបរិក្ខារ និងថ្លៃចំណាយលើបុគ្គលិក (មិនរួមបញ្ចូលនៅក្នុងខែវិច្ឆិកា ឆ្នាំ2020)។ ថវិកាជំនួយរដ្ឋនិងសហព័ន្ធ បានទូទាត់សងការកើនឡើងថ្លៃចំណាយភាគច្រើនដែលពាក់ព័ន្ធនឹងឯកសារនិងសកម្មភាពផ្សព្វផ្សាយ និងបានផ្តល់ជំនួយច្រើនគួរឲ្យកត់សម្គាល់ក្នុងការដោះស្រាយបញ្ហាអនុវត្តការបោះឆ្នោតទូទាំងរដ្ឋ នៅអំឡុងពេលជំងឺរាតត្បាត COVID-19។

សេចក្តីព្រាងច្បាប់នៃសភាតំណាងរាស្ត្រថ្នាក់រដ្ឋលេខ 37 ក្នុងឆ្នាំ2021 និងរាល់លក្ខខណ្ឌតម្រូវនៃច្បាប់ដែលកំណត់ឲ្យខោនធីទាំងអស់ផ្ញើសន្លឹកឆ្នោតបោះតាមសំបុត្រប្រៃសណីយ៍ទៅកាន់អ្នកបោះឆ្នោតសកម្មដែលបានចុះឈ្មោះ នឹងលុបបំបាត់ការកើនឡើងនៃថ្លៃប្រៃសណីយ៍ដែលបានសង្កេតឃើញ ចេញពីថ្លៃចំណាយដែលបានបូកបន្ថែមនៃគំរូ VCA។